វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប



ដើម្បីអភិវឌ្ឍន៍ជលផលទឹកសាបកម្ពុជាដោយនិរន្តរភាព

WorldFish CENTER

ឯកសារសង្ខេប

# តម្លៃសេដ្ឋកិច្ចសង្គម និង ការចិញ្ចឹមជីវិតនៃជលផលបឹងទន្លេសាប


ហាប ណាវី

សេង លាង

រតនា ឈឿនផាកឌី





ADB TA 4563-CAM

ការកសាងសមត្ថភាព នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (វគ្គ២)



អាគារលេខ ១៨៦, មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា, ប្រអប់សំបុត្រលេខ ៥៨២, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២២០ ៨១៧

អ៊ីម៉ែល: info@ifredi.org គេហទំព័រ: www.ifredi.org

# តំលៃសេដ្ឋកិច្ចសង្គម និង ការចិញ្ចឹមជីវិតនៃជលផលបឹងទន្លេសាប

ហាប ណាវី
សេង លាង
រតនា ឈឿនផាកឌី

ឆ្នាំ ២០០៦

បោះពុម្ពផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI) នៃរដ្ឋបាលជលផល
អាសយដ្ឋាន : អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Hap, N., Seng, L. and Chuenpagdee, R. 2006. Socioeconomics and Livelihood Values of Tonle Sap Lake Fisheries. Inland Fisheries Research and Development Institute, Phnom Penh, Cambodia. 32 pp.

ឯកសារសង្ខេបនេះត្រូវបានរៀបរៀងឡើង ជាផ្នែកមួយនៃជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាបដែលបានអនុវត្តដោយមជ្ឈមណ្ឌលត្រី ពិភពលោក និងគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (TA 4563-CAM).

នេះមិនមែនជាការបោះពុម្ពផ្សាយជាផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទេ ហើយទស្សនៈដែលបានឆ្លុះបញ្ចាំងនៅទីនេះ មិនទាក់ទងនឹងធនាគារអភិវឌ្ឍន៍អាស៊ីឡើយ ។

ISBN: 999506502-9
9789995065027

បោះពុម្ពដោយ D-Offset Printing House, 012 988 908

ម.ឯ.ឯ.ក AIDOC
Code: 147-037
Date:
Donated by:

# តម្លៃសេដ្ឋកិច្ចសង្គម និង ការចិញ្ចឹមជីវិតនៃជលផលបឹងទន្លេសាប

ហាប ណាវី[១]
សេង លាង[២]
រតនា ឈឿនផាកឌី[៣]

---

[១] ប្រធានការិយាល័យសេដ្ឋកិច្ចសង្គមនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប នាយកដ្ឋានជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ កម្ពុជា

[២] មន្ត្រីការិយាល័យសេដ្ឋកិច្ចសង្គមនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប នាយកដ្ឋានជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ កម្ពុជា

[៣] អ្នកវិទ្យាសាស្ត្រ នៃមជ្ឈមណ្ឌលត្រីពិភពលោក រាជធានីភ្នំពេញ កម្ពុជា

# មាតិកា


បញ្ជីតារាង. បញ្ជីរូប. ........ iii

សេចក្តីថ្លែងអំណរគុណ ........ iv

សេចក្តីសង្ខេប ........ v

១. សេចក្តីផ្តើម ........ ១

២. សកម្មភាពនិងចរិតលក្ខណៈរបស់សហគមន៍នៅតំបន់បឹងទន្លេសាប ........ ១

៣. យុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិតនិងការពឹងផ្អែកទៅលើធនធានវារិជាត ........ ៧

៤. តំលៃនៃធនធានជលផល និងធនធានវារិជាត ........ ១០

៥. បញ្ហានិងផលវិបាកក្នុងការទ្រទ្រង់ដល់ការធ្វើនេសាទដើម្បីចិញ្ចឹមជីវិត ........ ១៧

៦. សេចក្តីសន្និដ្ឋាន ........ ២២

ឯកសារយោង ........ ២៥

## បញ្ជីតារាង

តារាងទី ១: ភាគរយនៃគ្រួសារ បានចូលរួមនេសាទនៅតាមរដូវ និង ប្រភេទភូមិ

(៤៥គ្រួសារ នៅក្នុងនៅក្នុងភូមិនៃខេត្តនិមួយៗ) ........................................ ៣

តារាងទី ២: ផលចាប់ជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារ និងការប្រើប្រាស់នៅខេត្តកំពង់ចាម និងសៀមរាបទៅតាមប្រភេទភូមិ ........................................ ៤

តារាងទី ៣: ភាគរយនៃគ្រួសារដែលបានចូលរួមនៅក្នុងសកម្មភាពរកប្រាក់ចំណូលផ្សេងៗ ទៅតាមប្រភេទភូមិ ........................................ ៦

តារាងទី ៤: សារៈសំខាន់នៃធនធានធម្មជាតិជាសាធារណៈដោយផ្អែកលើរបាយការណ៍ នៃការប្រើប្រាស់តាមរយៈការអង្កេតគ្រួសារនៅខេត្តកំពង់ឆ្នាំង និង សៀមរាប........ ៩

តារាងទី ៥: ការបែងចែកជាភាគរយនៃមេគ្រួសារជាបុរស និងស្ត្រីតាមរយៈមុខរបរនិងប្រភេទភូមិ.... ៩

តារាងទី ៦: ការប៉ាន់ស្មានប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារ(ជាដុល្លារ)ពីប្រភពទាំងអស់ តាមប្រភេទកំរិតប្រាក់ចំនូល តាមប្រភេទភូមិ និង តាមខេត្ត........................................ ១២

តារាងទី ៧: ប្រាក់ចំណូល "ដុល" សរុបសំរាប់គ្រួសារដែលពឹងផ្អែកលើ ប្រភពធនធានវារីជាតនៃបឹងទន្លេសាប ........................................ ១៤

តារាងទី ៨: តំលៃប្រើប្រាស់នៃជលផល ........................................ ១៦

តារាងទី ៩: សង្ខេបនៃចំលើយដែលចាំបាច់ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការធ្វើអោយមាន និរន្តភាពនៃរបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលរស់នៅក្នុង និងជុំវិញបឹងទន្លេសាប............ ១៩

## បញ្ជីរូប

រូបទី ១: ប្រភេទផ្សេងៗនៃតំលៃដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធវារីអេកូឡូស៊ី នៅតំបន់បឹងទន្លេសាប ........................................ ១១

រូបទី ២: ភាគរយនៃការបែងចែកគ្រួសារតាមកំរិតប្រាក់ចំណូលសំរាប់ប្រភេទភូមិនិមួយៗ................ ១៣

រូបទី ៣: ភាគរយនៃការបែងចែកចំនួនគ្រួសារនិងការប៉ាន់ស្មានប្រាក់ចំណូលសរុបប្រចាំឆ្នាំ តាមកំរិតប្រាក់ចំណូល (ប៉ាន់ស្មានសំរាប់ប្រាំខេត្ត)........................................ ១៥

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណនូវការផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank ADB) ក្រោមគំរោង ADB-TA 4563-CAM (ការកសាងសមត្ថភាពនៅក្នុងវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាបដំណាក់កាលទី II) ដែលជួយបង្កើតអោយមានការស្រាវជ្រាវនេះ។ យើងសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **ណៅ ធួក** លោកបណ្ឌិត **ចន គូរៀន** (Dr. John Kurien) លោកបណ្ឌិត **ប្លេក រ៉ាតណឺ** (Dr. Blake Ratner) កញ្ញា **យូមីកូ គូរ៉ា** (Ms. Yumiko Kura) និង លោក **ម៉ាកូ កេស្គីនិន** (Mr. Marko Keskinen) រាល់ការជួយពិនិត្យឡើងវិញលើរបាយការណ៍ព្រាងនិងជួយផ្តល់នូវការរិះគន់ដ៏មានប្រយោជន៍ជាច្រើន។ យើងសូមថ្លែងអំណរគុណជាពិសេសចំពោះ អ្នកស្រី **អេមិលីតា អាគបាយ៉ានី** (Mrs. Emelita C. Agbayani) និង លោក **រ៉េណាតូ អាគបាយ៉ានី** (Mr. Renato F. Agbayani) នូវរាល់ការផ្តល់យោបល់និងកែសំរួល។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក **តារុណ កាន់ដារិទ្ធ** ដែលបានជួយក្នុងការវិភាគទិន្នន័យ និងការរៀបចំរចនាតារាងនិងចតុរូបភាពនានា។ យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះ មន្ត្រីនៃការិយាល័យជលផលប្រចាំខេត្តទាំងប្រាំ មន្ត្រីរដ្ឋាភិបាលនៃអន្តរក្រសួង និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន និងអ្នកចូលរួមនៅក្នុងសិក្ខាសាលា ដែលបានចែករំលែកនូវរាល់ចំណេះដឹង បទពិសោធន៍ និងទស្សនវិស័យ របស់ពួកគេនៅក្នុងរបាយការណ៍នេះ។ ទស្សនៈ និង មតិយោបល់ដែលមាននៅក្នុងរបាយការណ៍នេះ គឺជារបស់អ្នកនិពន្ធ ប៉ុន្តែមិនមែនតំណាងអោយអង្គការឬស្ថាប័នរបស់ពួកគេឡើយ។ ជាចុងក្រោយនេះ អ្នកនិពន្ធទទួលខុសត្រូវចំពោះរាល់កំហុសឆ្គងនានា និង/ឬ ការខ្វះខាតដែលមាន នៅក្នុងរបាយការណ៍នេះ។

## សេចក្ដីសង្ខេប

## តំលៃសេដ្ឋកិច្ចសង្គម និង ការចិញ្ចឹមជីវិតនៃជលផលបឹងទន្លេសាប

ដោយ

ហាប ណាវី, សេង លាង និង រតនា ឈឿនផាកឌី

ធនធានជលផលនៅក្នុងតំបន់បឹងទន្លេសាប គឺមានសារៈសំខាន់មិនអាចកាត់ថ្លៃបានទេ ហើយបានចូលរួមចំណែកយ៉ាងច្រើន (ប្រហែល៦០%) នៃផលិតផលនេសាទទឹកសាបសរុប។ អ្វីដែលមិនទាន់ត្រូវបានទទួលស្គាល់ នោះគឺសារៈសំខាន់នៃប្រពន្ធ័វារីអេកូឡូស៊ីនៃបឹងទន្លេសាបចំពោះការចិញ្ចឹមជីវិតរបស់ប្រជាជនជាងមួយលាននាក់ដែលរស់នៅក្នុង និង ជុំវិញតំបន់នោះ ហើយព្រមទាំងពឹងផ្អែកយ៉ាងខ្លាំង (តែមិនទាំងស្រុងទេ) ទៅលើធនធានទាំងនោះ។ របាយការណ៍សង្ខេបនេះ គឺដកស្រង់ចេញពីការសិក្សាថ្មីៗមួយដែលផ្ដល់នូវការប៉ាន់ស្មានតំលៃរបស់ធនធានជលផលនិងវារីជាត ចំពោះសហគមន៍ទាំងឡាយនៅក្នុងខេត្តទាំងប្រាំដែលមានព្រំប្រទល់ជាប់នឹងបឹង ទន្លេសាប ដូចជា ខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងកំពង់ធំ។ របាយការណ៍នេះបង្ហាញអោយឃើញថា គ្រួសារទាំងអស់នៅក្នុងតំបន់ទាំងនោះចូលរួមក្នុងសកម្មភាពប្រកបរបរ ចិញ្ចឹមជីវិត និងរកប្រាក់ចំណូលផ្សេងៗរួមមាន ការធ្វើនេសាទ ការកែច្នៃត្រី ការទិញលក់ត្រី ការចិញ្ចឹមត្រី ការធ្វើស្រែ កម្មករ ប្រចាំថ្ងៃ និងប្រមូលអុស ដោយឥតគិតអំពីមុខរបរចំបងរបស់ពួកគេឡើយ។ ចំណូលសរុបប្រចាំឆ្នាំនៃគ្រួសារដែលបានមកពីការប្រើប្រាស់ដោយផ្ទាល់នៃភោគផលរបស់គ្រួសារដែលពឹងផ្អែកទៅលើធនធានជលផលនៅក្នុងខេត្តទាំងប្រាំ ត្រូវបានប៉ាន់ស្មានសរុបប្រហែលជា ២៣៣ លានដុល្លារអាមេរិក។ មានតែមួយភាគបីនៃចំនួននោះតែប៉ុណ្ណោះដែលត្រូវទទួលបានដោយគ្រួសារដែលមានចំណូលតិចជាង ១.០០០ដុល្លារអាមេរិក ហើយដែលរួមមាន ប្រហែលជា ៧២% នៃចំនួនគ្រួសារសរុប។ ចំពោះគ្រួសារដែលមានចំណូលទាបទាំងនោះ គឺភាគច្រើនជាអ្នកនេសាទជាលក្ខណៈគ្រួសារនិងសំរាប់បរិភោគតែប៉ុណ្ណោះ និងកសិករដែលចិញ្ចឹមជីវិតដោយពឹងផ្អែកយ៉ាងខ្លាំងទៅលើបឹងទន្លេសាប។ ជាការពិតណាស់ ទាក់ទងទៅនឹងរបរចិញ្ចឹមជីវិតរបស់ពួកគេ ដូចជាការធានានូវសិទ្ធិនៃការប្រើប្រាស់ធនធាននានានិងសិទ្ធិចាំបាច់ចំពោះសុវត្ថិភាពស្បៀង ការងារ ការអប់រំ និងការរក្សាសុខភាពគួរតែត្រូវបានបញ្ជាក់អោយបានច្បាស់នៅក្នុងកិច្ចពិភាក្សាអំពីការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានជលផល និងប្រពន្ធ័វារីអេកូឡូស៊ីនៃបឹងទន្លេសាប។

## ១. សេចក្តីផ្តើម

របាយការណ៍សង្ខេបនេះមានគោលបំណងបកស្រាយអំពីចរិតលក្ខណៈនៃសេដ្ឋកិច្ចសង្គមរបស់សហគមន៍នេសាទនៅជុំវិញបឹងទន្លេសាប និង សង្ខេបនូវព័ត៌មានស្តីពីតំលៃនៃការចិញ្ចឹមជីវិត និង សេដ្ឋកិច្ចរបស់ធនធានជលផលចំពោះសហគមន៍ទាំងនោះ ហើយនឹង ដើម្បីកំណត់នូវបញ្ហាសំខាន់ៗដែលគួរលើកយកមកពិចារណាក្នុងការធ្វើអោយមាននិរន្តភាពនៃការប្រកបមុខរបររបស់ពួកគេ។ សេចក្តីសង្ខេបនេះបានដកស្រង់មួយចំនួន ធំចេញអំពីការសិក្សាស្តីអំពីសេដ្ឋកិច្ចសង្គមថ្មីៗនេះ និង ការប្រកបរបចិញ្ចឹមជីវិតដោយពឹងផ្អែកទៅលើធនធាន ជលផលនៅក្នុងបឹងទន្លេសាប[៤] ជាពិសេសនៅក្នុងរបាយ ការរបស់ (Rab *et al.* 2005) និង (Ahmed *et al.* 1998) ហើយរបាយការណ៍ទាំងពីរនេះបានផ្តល់នូវព័ត៌ មានជាមូលដ្ឋាននៃសេដ្ឋកិច្ចសង្គមស្តីពីសហគមន៍ ដែលស្ថិតនៅជុំវិញបឹងទន្លេសាបក្នុងរយៈពេលពីរខុសគ្នា[៥]។ របាយការណ៍សង្ខេបនេះ គឺផ្តោតសំខាន់ទៅលើខេត្តប្រាំ ដែលមានព្រំប្រទល់ជាប់នឹងបឹងទន្លេសាប ដូចជាខេត្ត សៀមរាប បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ធំ។ ជាដំបូងយើងធ្វើការបកស្រាយអំពីសហគមន៍នានានៅ ក្នុងបឹងទន្លេសាបនិងសកម្មភាពនេសាទ សកម្មភាពទាក់ទងនឹងការធ្វើនេសាទ ហើយនឹងសកម្មភាពរកប្រាក់ ចំណូលផ្សេងៗទៀតរបស់ពួកគេ។ បន្ទាប់មកទៀត យើងនឹងធ្វើការសង្ខេបជាទូទៅលើយុទ្ធសាស្ត្រនៃការប្រកបរបចិញ្ចឹមជីវិត ព្រមទាំងភាពពឹងផ្អែកទៅលើធនធានវារិជាតរបស់ពួកគេ។ ដូច្នេះហើយយើងនឹង ទាញយកមកធ្វើការពិចារណាអំពី "តំលៃ" ឬ សារៈសំខាន់នៃធនធានជលផលនិងធនធានវារិជាតផ្សេងៗទៀត ដោយផ្អែកទៅលើការសិក្សាស្រាវជ្រាវ ដែលបានធ្វើឡើងដោយ (Rab *et al.* 2005)[៦]។ ជាចុងក្រោយ យើងធ្វើការសន្និដ្ឋានដោយមានបញ្ហាសំខាន់ៗ ដែលជាគន្លឹះនិងផលវិបាកក្នុងការធ្វើអោយមាននិរន្តរភាពនៃការប្រកបរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍នេសាទទាំងឡាយនៅក្នុង និង ជុំវិញបឹងទន្លេសាប។

## ២. សកម្មភាពនិងចរិតលក្ខណៈរបស់សហគមន៍នៅតំបន់បឹងទន្លេសាប

ជលផលគឺជាធនធានចំបងសំរាប់ការរស់នៅរបស់ប្រជាជនកម្ពុជាជាយូរលង់ណាស់មកហើយ ជាពិសេសចំពោះ ការរស់នៅរបស់សហគមន៍នៅក្នុង និងជុំវិញបឹងទន្លេសាបតែម្តង។ ធនធានជលផលដែលបានមកពីតំបន់បឹងទន្លេសាប ចូលរួមចំណែកប្រហែលជា ៥៧ ទៅ ៦២% នៃផលិតផលនេសាទទឹកសាបសរុបរបស់ប្រទេសកម្ពុជា (Baran, 2005) ឬប្រហែលជា ២00.000 ទៅ ២១៨.000តោន ដោយផ្អែកទៅលើផលនេសាទសរុបជាមធ្យមក្នុងកំឡុងឆ្នាំពី ២00១ ដល់ ២00៣ (DoF, 2004) ដែលស្មើរនឹងតំលៃចន្លោះពី ១៥0 ទៅ ២៥0 លានដុល្លារអាមេរិច[៧] (MAFF-CNMC, 2003)។ យោងទៅតាមការសិក្សាដែលធ្វើឡើងនៅក្នុងឆ្នាំ

---

[៤] ពាក្យថា "បឹងទន្លេសាប" ដែលប្រើនៅទីនេះគឺបញ្ជាក់អំពីការផ្តោតសំខាន់ទៅលើតំបន់បឹង និងវាលលិចទឹកហើយមិនសំដៅទៅលើទន្លេសាបដែលភ្ជាប់បឹងជាមួយនឹងទន្លេមេគង្គទេ។ ពាក្យថាបឹងទន្លេសាប ទន្លេសាប និង បឹងធំ ត្រូវបានប្រើក្នុងន័យ ដូចគ្នានៅក្នុងរបាយការណ៍នេះ។

[៥] តំបន់ដែលសិក្សានៅក្នុង Rab *et al.* (2005) រួមមាន កំពង់ឆ្នាំង សៀមរាប និង កណ្តាល ហើយជាផ្នែកមួយដែលមាននៅ ក្នុង Ahmed *et al.*(1998) ដោយរួមបញ្ចូលទាំង កំពង់ធំ បាត់ដំបង ពោធិសាត់ កំពង់ចាម និង ភ្នំពេញ។ ការសិក្សារបស់ Ahmed *et al.*(1998) ត្រូវបានធ្វើឡើងចន្លោះឆ្នាំ ១៩៩៥-១៩៩៦ រីឯ Rab *et al.* (2005) ត្រូវបានធ្វើឡើងចន្លោះឆ្នាំ ២00៣-២00៤។

[៦] តួរលេខដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍សង្ខេបនេះត្រូវបានធ្វើការវិភាគឡើងវិញតាមរយៈទិន្នន័យទទួលបានពីការ អង្កេតរបស់ Rab *et al.* (2005) ដើម្បីបញ្ចូលព័ត៌មានតែពីរខេត្តប៉ុណ្ណោះ គឺ កំពង់ឆ្នាំង និង សៀមរាប។ ដូច្នេះ វាខុសពីអ្វីដែល ត្រូវបានរាយការណ៍នៅក្នុង Rab *et al.* (2005)

[៧] អត្រាប្តូរប្រាក់ដែលអនុវត្តន៍នៅក្នុងការសិក្សានេះគឺ ១ ដុល្លារអាមេរិក = ៤000 រៀល

១៩៩៥ ដែលមានចំនងជើងថា "**ការវាយតំលៃសេដ្ឋកិច្ចសង្គមនៃផលនេសាទទឹកសាបរបស់ប្រទេសកម្ពុជា**" (Ahmed *et al.*,1998) បានអោយដឹងថាមានប្រជាជនសរុបប្រហែលជា ១.១៧ លាននាក់ នៅក្នុងខេត្តទាំងប្រាំ (មានប្រហែលជា ១៤៥សហគមន៍នេសាទ និង ១៩៥.000គ្រួសារនេសាទ) ដែលពឹងផ្អែកទៅលើធនធានជលផលនិងធនធានវារិជាតផ្សេងៗទៀតសំរាប់ជា ម្ហូបអាហារ ជាចំណូល និង ជារបរចិញ្ចឹមជីវិត។ នៅក្នុងឆ្នាំ២០០៣ ចំនួនប្រជាជនត្រូវបានប៉ាន់ស្មានថាមានការ កើនឡើងដល់ទៅ១.២៥លាននាក់ (Rab *et al.*,2005)។

*ជលផលគឺជាធនធានមួយយ៉ាងសំខាន់សំរាប់ការរស់នៅរបស់ប្រជាជនកម្ពុជាជាយូរលង់ណាស់មកហើយ។ ជាពិសេសប្រហែលជា ១.២៥ លាននាក់នៃប្រជាជនរស់នៅក្នុង៥ខេត្តជុំវិញបឹងទន្លេសាបដែលពឹងផ្អែកលើធនធានជលផល និងធនធានវារិជាតសំរាប់ជាម្ហូបអាហារ ជាប្រាក់ចំណូល និងជារបរចិញ្ចឹមជីវិត។*

ជាទូទៅ ការនេសាទត្រូវបានបែងចែកជាបីប្រភេទផ្សេងៗគ្នាដូចជា ការនេសាទជាលក្ខណៈគ្រួសារ (ទ្រង់ទ្រាយតូច) ការនេសាទជាលក្ខណៈមធ្យម (សិប្បកម្ម) និង ការនេសាទជាលក្ខណៈឧស្សាហកម្មឬទ្រង់ទ្រាយធំ (ឡូតិ៍នេសាទ)[៥] ។ ការបកស្រាយដោយសង្ខេបនៃប្រភេទនេសាទទាំងនោះ ត្រូវបានលើកមកពន្យល់ដូចខាងក្រោម ជាមួយនឹងការប៉ាន់ស្មានទូវផលនេសាទក្នុងឆ្នាំ ១៩៩៥ ដូចបានសរសេរនៅក្នុង (Ahmed *et al.* 1998) ដោយផ្អែកទៅលើការស្ទង់មតិទិន្នន័យទៅលើអ្នកនេសាទជាលក្ខណៈគ្រួសារចំនួន៨៦៧គ្រួសារ អ្នកនេសាទ ជាលក្ខណៈមធ្យមចំនួន ៨៤គ្រួសារ និង ឡូតិ៍នេសាទចំនួន ៦ ដែលចាត់ទុកថាទាក់ទងទៅនឹងសកម្មភាពនេសាទយ៉ាងសកម្ម នៅក្នុងរយៈពេលនៃការស្ទង់ទិន្នន័យនោះ។ ទោះបីជាយ៉ាងណាក៏ដោយវាគួរអោយកត់សំគាល់ផងដែរថាការប៉ាន់ស្មាននៅឆ្នាំ១៩៩៥ហាក់ដូចជាមានភាពខុសគ្នាយ៉ាងពិតប្រាកដមួយអំពីតួលេខបច្ចុប្បន្ន ដោយចាត់ទុកថាកំណែទំរង់ជលផលថ្មីនេះ អាចបណ្តាលអោយមានការកើនឡើងនូវចំនួនគ្រួសារនេសាទ។

i. *ការនេសាទជាលក្ខណៈគ្រួសារ (ទ្រង់ទ្រាយតូច)*: ការនេសាទប្រភេទនេះត្រូវបានអនុវត្តស្ទើរតែគ្រប់គ្រួសារដែលរស់នៅជុំវិញបឹងទន្លេសាប ហើយជាធម្មតាគឺត្រូវធ្វើឡើងដោយសមាជិកគ្រួសារ និងប្រើប្រាស់ឧបករណ៍នេសាទតូចៗ ដូចជា មង និងលបជាដើម។ ការនេសាទនេះត្រូវធ្វើឡើងដោយមិនចាំបាច់មានលិខិតអនុញ្ញាត និងអាចធ្វើនេសាទបានពេញមួយឆ្នាំ។ ចំពោះបរិមាណនៃផលនេសាទត្រូវបានប្រើប្រាស់ដើម្បីផ្គត់ផ្គង់ក្នុងផ្ទះ។ គ្រួសារភាគច្រើនបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនេសាទ គឺមាន ៩០% នៃចំនួនគ្រួសារសរុបធ្វើនេសាទជាលក្ខណៈគ្រួសារ។ នៅឆ្នាំ១៩៩៥ មានចំនួនប្រហែល ៨៥.000គ្រួសារ ដែលធ្វើនេសាទទ្រង់ទ្រាយតូច និងតាមការប៉ាន់ស្មានផលចាប់ជាមធ្យមប្រចាំឆ្នាំ គឺប្រហែលជា ០.៧ តោនក្នុងមួយគ្រួសារ។ មានជាងពីរភាគបីនៃផលនេសាទគ្រួសារសរុប ដែលបានមកពីខេត្តកំពង់ឆ្នាំង និង ខេត្តបាត់ដំបង។

ii. *ការនេសាទជាលក្ខណៈមធ្យម*: ការធ្វើនេសាទប្រភេទនេះគឺមានលក្ខណៈជាពាណិជ្ជកម្ម និងត្រូវបាន អនុញ្ញាតអោយធ្វើនេសាទតែក្នុងចន្លោះពេលពីខែតុលាដល់ខែឧសភាតែប៉ុណ្ណោះ គឺនៅពេលដែលកំរិតទឹកនៅក្នុងបឹងទន្លេសាបចាប់ផ្តើមស្រកចុះហើយទំហំនៃតំបន់លិចទឹកក៏រួមតូចទៅៗ។ តាមបទបញ្ញាបច្ចុប្បន្ន ការធ្វើនេសាទប្រភេទនេះមិនចាំបាច់បង់ពន្ធទេ។ រីឯប្រភេទឧបករណ៍នេសាទវិញ

[៥] សូមមើលការបកស្រាយលំអិតនៃប្រភេទការនេសាទនៅក្នុង Baran (2005)

មង គឺជាឧបករណ៍មួយដ៏សំខាន់សំរាប់អ្នកនេសាទប្រភេទនេះ។ ចំណែកឯ ចំនួនគ្រួសារនេសាទជាលក្ខណៈមធ្យមនៅខេត្តទាំងប្រាំនៅក្នុងឆ្នាំ១៩៩៥ គឺមានប្រហែលជា ៩.០០០គ្រួសារ ហើយនឹងមានផលចាប់សរុបជាមធ្យមប្រហែលជា ៥.៣ តោនក្នុងមួយឆ្នាំក្នុងមួយគ្រួសារ។

iii. *ការនេសាទជាលក្ខណៈឧស្សាហកម្ម ឬ ឡូតិ៍នេសាទ:* វាត្រូវអនុវត្តទៅតាមប្រព័ន្ធនៃការជួលដេញថ្លៃពីរឆ្នាំម្តង ហើយអាចប្រើប្រាស់ឧបករណ៍ជាច្រើនដែលអាចគ្របដណ្តប់លើផ្ទៃទឹកយ៉ាងធំដូចជា ដាយ និង អូន។ នៅឆ្នាំ ១៩៩៥ ផលចាប់ប្រចាំឆ្នាំជាមធ្យម គឺប្រហែលជា ៩៤.១ តោនក្នុងឡូតិ៍នេសាទមួយ។

ជាទូទៅការនេសាទធ្វើឡើងនៅក្នុងបឹងទន្លេសាប និងនៅក្នុងទន្លេ ស្ទឹង ព្រៃលិចទឹក និងវាលស្រែលិចទឹកផងដែរ។ ការនេសាទនៅក្នុងវាលស្រែភាគច្រើនធ្វើនៅក្នុងរដូវបិទនេសាទ (ពីខែមិថុនាដល់ខែកញ្ញា)។ រីឯកន្លែងនេសាទផ្សេងៗទៀត គឺអនុញ្ញាតអោយធ្វើនេសាទពេញមួយឆ្នាំសំរាប់ នេសាទជាលក្ខណៈគ្រួសារ។

យោងទៅតាម Rab *et al.* (2005) ភូមិដែលនៅជុំវិញបឹងទន្លេសាបអាចត្រូវបានបែងចែកខុសៗគ្នា ដោយផ្អែកទៅលើកំរិតនៃសកម្មភាពនេសាទរបស់គ្រួសារនិមួយៗ រួមមានប្រភេទភូមិនេសាទ ភូមិនេសាទផងនិងធ្វើស្រែផង និង ភូមិធ្វើស្រែសុទ្ធ។ ចំពោះប្រភេទភូមិនេសាទសុទ្ធ គឺជាភូមិដែលមានចំនួនគ្រួសារពី ៨០ ទៅ ៩០% ដែលចាត់ទុកថា ការធ្វើនេសាទជាមុខរបរចំបងរបស់ពួកគេ។ រីឯប្រភេទភូមិធ្វើស្រែសុទ្ធវិញ គឺជាភូមិដែលមាន ចំនួនគ្រួសារយ៉ាងតិច ៨០% ដែលចាត់ទុកថាការធ្វើស្រែចំការជាមុខរបរចំបង។ ចំណែកឯប្រភេទភូមិនេសាទផងនិងធ្វើស្រែផង គឺជាភូមិដែលគ្រួសារទាំងនោះពឹងផ្អែកទៅលើការធ្វើនេសាទនៅក្នុងរដូវវស្សា និងធ្វើស្រែនៅរដូវប្រាំង។ យោងទៅតាមការស្រង់ព័ត៌មានទៅលើ ២៧០គ្រួសារនៅក្នុង ខេត្តកំពង់ឆ្នាំង និងសៀមរាប ឆ្នាំ ២០០៣-២០០៤ (Rab *et al.*, 2005) មានស្ទើរតែគ្រប់គ្រួសារទាំងអស់នៅក្នុងភូមិនេសាទ និងមានប្រហែលជា ៦៦% នៃគ្រួសារក្នុងភូមិនេសាទផងនិងធ្វើស្រែផង ដែលធ្វើនេសាទពេញមួយឆ្នាំ (តារាងទី១)។ ម្យ៉ាងវិញទៀត នៅក្នុងភូមិធ្វើស្រែសុទ្ធ មានជិតពាក់កណ្តាលនៃគ្រួសារធ្វើនេសាទនៅក្នុងរដូវបិទ ព្រោះពេលនោះគឺជាពេលដែល កំរិតទឹកនៅខ្ពស់ហើយគេពុំអាចធ្វើស្រែឬដាំដំណាំផ្សេងៗបាន។

ដូចបានរៀបរាប់ពីមុនមកហើយ ប្រភេទនៃឧបករណ៍នេសាទដែលបានប្រើប្រាស់ប្រែប្រួលទៅតាមប្រភេទនេសាទ ទីកន្លែងនេសាទ និងប្រភេទត្រីដែលពួកគេចាប់បាន។ មង គឺជាឧបករណ៍ដែលគេចូលចិត្តប្រើជាងគេក្នុងការធ្វើនេសាទជាលក្ខណៈគ្រួសារ ដោយហេតុថាគេចាត់ទុកវាជាប្រភេទឧបករណ៍ដែលមានតំលៃថោក ហើយសមស្របជាមួយនឹងការចាប់ត្រីបានច្រើនប្រភេទតាមកន្លែងនេសាទខុសៗគ្នា។ ដូច្នេះមានប្រហែលជា ៧៣% (២៧០) នៃគ្រួសារសរុប និងមាន ៦២% នៅក្នុងប្រភេទភូមិធ្វើស្រែសុទ្ធ និង ៨៤% ក្នុងភូមិនេសាទសុទ្ធ ហើយពួកគេទាំងអស់មានមងផ្ទាល់ខ្លួន (Rab *et al.*, (2005)។ ប្រភេទត្រីសំខាន់ៗដែលចាប់បានដោយគិតជា បរិមាណមាន ចន្លោះពី ១៣



តារាងទី១: ភាគរយនៃគ្រួសារ បានចូលរួមនេសាទនៅតាមរដូវ និង ប្រភេទភូមិ (៤៥ នៅក្នុងនៅក្នុងភូមិនៃខេត្តនិមួយៗ)

| ប្រភេទនៃការនេសាទ | ខេត្តកំពង់ឆ្នាំង | | | ខេត្តសៀមរាប | | | ទាំងពីរខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែសុទ្ធ | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែសុទ្ធ | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែសុទ្ធ |
| រដូវបិទ | 2 | 7 | 49 | 0 | 4 | 44 | 1 | 6 | 47 |
| រដូវបើក | 7 | 13 | 0 | 2 | 22 | 9 | 4 | 18 | 4 |
| ពេញមួយឆ្នាំ | 89 | 71 | 18 | 98 | 60 | 31 | 93 | 66 | 24 |
| តាមរដូវកាល រឺ មិននេសាទ | 2 | 9 | 33 | 0 | 13 | 16 | 1 | 11 | 24 |

ប្រភព: ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005)

ទៅ ៣៦% នៃផលចាប់សរុប។ ចំពោះគ្រប់ប្រភេទនៃការនេសាទគឺជាប្រភេទ ត្រីស្រកា (ត្រីរៀល Henicorhychus spp.)។ រីឯប្រភេទត្រីសំខាន់ៗផ្សេងទៀតរួមមាន ត្រីរស់ ត្រីអណ្តែង និង ប្រភេទត្រីមានស្រកា (Cyprinids) ផ្សេងៗទៀត។

មានភាពខុសគ្នាខ្លះៗ ចំពោះផលចាប់ប្រចាំឆ្នាំជាមធ្យមក្នុងមួយគ្រួសាររវាងខេត្តកំពង់ឆ្នាំងនិងខេត្តបាត់ដំបងដែលអាចត្រូវបានសង្កេតនៅក្នុង Rab *et al.*, (2005)។ ផលចាប់ប្រចាំឆ្នាំនៃគ្រួសារក្នុងភូមិនេសាទនៃខេត្តទាំងពីរ គឺ ច្រើនជាងគ្រួសារក្នុងភូមិនេសាទផងនិងធ្វើស្រែ ផងនិងភូមិធ្វើស្រែសុទ្ធ (ប្រហែលជា ៧៥% នៃផលនេសាទសរុបបានមកពីភូមិនេសាទ) (តារាងទី២)។ បើប្រៀបធៀបទៅតាមខេត្តវិញចំពោះផលចាប់ជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារនៅក្នុងភូមិនេសាទ និង ភូមិនេសាទផងនិងធ្វើស្រែផងតួលេខបានបង្ហាញថា ផលនេសាទរបស់គ្រួសារ គំរូនៅក្នុងខេត្តសៀមរាប ខ្ពស់ជាងពីរដងនៃផលចាប់របស់គ្រួសារគំរូក្នុងខេត្តកំពង់ឆ្នាំង។ នេះប្រហែលជាដោយសារនៅក្នុងខេត្តសៀមរាបមានអ្នកនេសាទសិប្បកម្ម និង ឡូត៍នេសាទច្រើន។ ទោះជាយ៉ាងណាក៏ដោយ ភាពផ្ទុយគ្នាត្រូវបានរកឃើញថា គ្រួសាររស់នៅក្នុងភូមិធ្វើស្រែសុទ្ធមានបរិមាណផលចាប់ខ្ពស់ជាងគេនៅខេត្តកំពង់ឆ្នាំង បើប្រៀបទៅនឹងខេត្តផ្សេងទៀត។

ម្យ៉ាងវិញទៀត ចំពោះការប្រើប្រាស់នៃផលនេសាទមានភាពខុសគ្នាទៅតាមប្រភេទភូមិនិងខេត្តផ្សេងៗគ្នា។ ឧទាហរណ៍ នៅក្នុងរបាយការណ៍ Rab *et al.* (2005) បានសរសេរថា ក្នុងចំណោមប្រភេទភូមិនេសាទនៅក្នុងខេត្តកំពង់ឆ្នាំង និង ខេត្តសៀមរាប មានប្រហែលជា ៨០% នៃផលនេសាទសរុបត្រូវបានលក់ស្រស់ ១% ប្រើសំរាប់ចំណីត្រី ៨% សំរាប់កែច្នៃ និងភាគរយដែលនៅសល់គឺ ៣% ត្រូវបានប្រើប្រាស់ឬហូបនៅក្នុងផ្ទះ។ គួរអោយកត់សំគាល់ថា ទោះជាយ៉ាងណាក៏ដោយភាគរយនៃផលនេសាទសំរាប់ប្រើប្រាស់នៅក្នុងផ្ទះគឺខ្ពស់ខ្លាំងនៅ ភូមិធ្វើស្រែ (ប្រហែលជា ៣៨%) បើប្រៀបធៀបទៅនឹងភូមិនេសាទ និងភូមិធ្វើនេសាទផងនិងធ្វើស្រែផង (តារាងទី២)។ ចំណែកឯផលនេសាទទាប និង សមាមាត្រនៃផលនេសាទសំរាប់ហូបក្នុងផ្ទះខ្ពស់វិញ គឺមានចំពោះអ្នកធ្វើនេសាទគ្រួសារនៅក្នុងភូមិធ្វើស្រែសុទ្ធ។

សកម្មភាពកែច្នៃត្រីអាចត្រូវបានបែងចែកភាគច្រើនដោយផ្អែកទៅលើទំហំនៃប្រតិបត្តិការ ដូចជា: (១) *ជាលក្ខណៈគ្រួសារ ឬ បុរាណ* គឺសំរាប់ប្រើប្រាស់

តារាងទី២: ផលចាប់ជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារ និងការប្រើប្រាស់នៅខេត្តកំពង់ចាមនិងសៀមរាបទៅតាមប្រភេទភូមិ

| ការប្រើប្រាស់នៃផលចាប់ (គីឡូក្រាម) | ខេត្តកំពង់ឆ្នាំង | | | ខេត្តសៀមរាប | | |
|---|---|---|---|---|---|---|
| | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ |
| សំរាប់ប្រើប្រាស់ក្នុងផ្ទះ | 136 | 172 | 150 | 723 | 240 | 128 |
| លក់ស្រស់ | 7,402 | 1,166 | 347 | 11,369 | 4,597 | 121 |
| កែច្នៃត្រី | 67 | 30 | 16 | 1,884 | 113 | 4 |
| ចំណីត្រី | 592 | 889 | 44 | 1,449 | 73 | 1 |
| ផលចាប់គ្រួសារប្រចាំឆ្នាំ | 8,197 | 2,257 | 557 | 15,425 | 5,023 | 254 |
| ការប្រើប្រាស់នៃផលចាប់ (%) | | | | | | |
| សំរាប់ប្រើប្រាស់ក្នុងផ្ទះ | 2 | 8 | 27 | 5 | 5 | 50 |
| លក់ស្រស់ | 90 | 52 | 62 | 74 | 92 | 48 |
| កែច្នៃត្រី | 1 | 1 | 3 | 12 | 2 | 2 |
| ចំណីត្រី | 7 | 39 | 8 | 9 | 1 | 0 |

ប្រភព: ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005)

ក្នុងផ្ទះ (២) *ជាលក្ខណៈសិប្បកម្ម* គឺមានកម្មករពី ៤០ ទៅ ៦០នាក់ ហើយភាគច្រើនការកែច្នៃប្រភេទនេះសំរាប់ទីផ្សារក្នុងស្រុក និង (៣) *ជាលក្ខណៈឧស្សាហកម្ម* គឺ សំរាប់ទីផ្សារអន្តរជាតិ។ ផលិតផលកែច្នៃដែលសំខាន់ជាងគេបើគិតពីបរិមាណផលិតគឺរួមមានប្រហុកពាក់កណ្តាលសំរេច (ប្រហែលជា ៧៣%) និង ប្រហុក (ប្រហែលជា ១៣%)។ ផលិតផលទាំងនោះត្រូវបានលក់ក្នុងតម្លៃមួយទាបជាងគេ (ប្រហែលជា ០.៣៥ ដុល្លារក្នុងមួយគីឡូក្រាម) បើប្រៀបធៀបផលិតផលផ្សេងទៀតដូចជាត្រីឆ្អើរ និង ផ្អក (តម្លៃចន្លោះពី ០.៦០ ទៅ ០.៧០ ដុល្លារក្នុងមួយគីឡូក្រាម) ដែលមានបរិមាណតិចតួចបំផុត។

ដូចគ្នាទៅនឹងការប្រើប្រាស់ត្រីដែលចាប់បានផងដែរ ចំពោះគ្រួសារធ្វើស្រែ ពួកគេតែងតែទុកផលិតផលកែច្នៃស្ទើរតែទាំងអស់ (ប្រហែល៩៥%) សំរាប់ហូបនៅក្នុងផ្ទះ និង ក្រៅពីនោះសំរាប់លក់។ ផ្ទុយទៅវិញ ចំពោះគ្រួសារនេសាទ ៩១% នៃផលិតផលកែច្នៃត្រូវបានយកទៅលក់ (Rab *et al.*, 2005)។ ជាទូទៅ ទោះបីជាមាន ៦៣% នៃគ្រួសារគំរូ (២៧០) បានរាយការណ៍ថា "ការកែច្នៃត្រី" គឺជាមុខរបរមួយរបស់ពួកគេក៏ដោយ ក៏មានតែ ១៦% នៃគ្រួសារសរុបតែប៉ុណ្ណោះដែលទទួលបានប្រាក់ចំណូលពីសកម្មភាពនេះ។ គេគួរកត់សំគាល់ផងដែរថា ស្ត្រី និង កុមារចូលរួមក្នុងសកម្មភាពកែច្នៃត្រីនេះ ហាក់ដូចជា មានចំនួនច្រើនជាងបើប្រៀបធៀបទៅនឹងការធ្វើ នេសាទដោយផ្ទាល់។ ឧទាហរណ៍ដូចជានៅក្នុងរោងចក្រ កែច្នៃត្រី មាន ៨០% នៃកម្មករជាស្ត្រី។

ផ្នែកវារីវប្បកម្ម គឺជាសកម្មភាពសេដ្ឋកិច្ចមួយផ្សេងទៀតដែលអាចរកប្រាក់ចំណូលបានច្រើនដែរ នៅក្នុងចំណោមសហគមន៍នានាដែលនៅក្នុង និង ជុំវិញបឹងទន្លេសាប។ នៅក្នុងប្រភេទភូមិនេសាទមួយចំនួន Rab *et al.* (2005) បានរកឃើញថាប្រហែលជាជិតពាក់កណ្តាលនៃគ្រួសារគំរូសរុបបានចូលរួមក្នុងការចិញ្ចឹមត្រី។ នៅក្នុងបឹងទន្លេសាបមានការចិញ្ចឹមត្រីពីរប្រភេទសំខាន់ៗ គឺចិញ្ចឹមត្រីតាមបែរនិងស៊ង ដែលមានប្រភេទត្រីមួយចំនួន រួមមាន ត្រីឆ្តោ ត្រីប្រា ត្រីពោ និង រ៉ស់ ហើយនឹងចិញ្ចឹមក្រពើ។ មានគ្រួសារភាគច្រើនបានចិញ្ចឹមត្រី ដែលពួកគេបានចាប់កូនត្រីពូជ ឬ ត្រីម្យៅពីធម្មជាតិ ហើយថែរក្សាទុកនៅក្នុងស៊ងឬបែរដែលមាននៅក្រោមផ្ទះបណ្តែតទឹករបស់ពួកគេ ដើម្បីថែរក្សាអោយបានធំធាត់ និង លក់នៅពេលដែលមានតំរូវការខ្ពស់។

ជាទូទៅ សកម្មភាពនេសាទ និង សកម្មភាពដែលទាក់ទងនឹងនេសាទ គឺមានសារៈសំខាន់យ៉ាងខ្លាំងសំរាប់គ្រួសារភាគច្រើននៅតំបន់បឹងទន្លេសាប។ គួរអោយកត់សំគាល់ថា ទោះបីជាមានការចូលរួមក្នុងសកម្មភាពទាំងពីរ ខាងលើច្រើនយ៉ាងណាក៏ដោយ តែគ្រួសារគំរូទាំងនោះនៅតែគិតថា ការធ្វើស្រែគឺជាមុខរបរចំបងរបស់ពួកគេដដែល។ ឧទាហរណ៍ ប្រហែលជា ៧២% (២៥៤៤) នៃគ្រួសារនៅក្នុងខេត្តគំរូទាំង៥របស់ Ahmed *et al.* (1998) បានរាយការណ៍ថា របរធ្វើស្រែជាមុខរបរសំខាន់របស់ពួកគេ ក្នុងនោះមានតែ ១២% គត់ដែលចាត់ទុកថា ការនេសាទគឺជាមុខរបរចំបងរបស់ពួកគេ។ នេះប្រហែលជាដោយសារតែជាមធ្យមមានភាគច្រើន ៩០% នៃ គ្រួសារទាំងនោះសាងសង់ផ្ទះរបស់គេនៅលើគោកឬលើដី។ អ្នកដែលសង់ផ្ទះនៅលើទឹកនៅក្នុងខេត្តកំពង់ឆ្នាំង បាត់ដំបង និងកំពង់ធំ គឺមានចំនួនច្រើនជាងគេប្រហែលជា ៧% (Ahmed *et al.*, 1998)។ ចំពោះមុខរបរចំបង ដែលត្រូវបានរាយការណ៍ ក្នុងន័យប្រាក់ចំណូលនិងការប្រើប្រាស់ពេលវេលានោះ ប្រហែលមិនមែនជាសូចនករណ៍ដ៏ល្អសំរាប់បង្ហាញពីសារៈសំខាន់ចំពោះអ្នកដែលពឹងផ្អែកទៅលើធនធានវារិជាត ក្នុងការចិញ្ចឹមជីវិតឡើយដោយហេតុថាមានប្រជាជន ជាច្រើនបានចូលរួមធ្វើនេសាទសំរាប់ប្រើប្រាស់ក្នុងគ្រួសារតែប៉ុណ្ណោះ ទោះបីពួកគេធ្វើនេសាទប្រចាំថ្ងៃ ឬ មិនជាប្រចាំក៏ដោយ។ លើសពីនេះទៅទៀតគ្រួសារភាគ ច្រើនបានគិតថានេសាទគឺមិនត្រឹមតែសំខាន់សំរាប់ការរក ប្រាក់ចំណូលប៉ុណ្ណោះទេ ថែមទាំងជាប្រភពយ៉ាងសំខាន់ នៃប្រូតេអ៊ីន និង មានសារៈសំខាន់ដើម្បីទប់ទល់ នៅពេលជំណាំខ្វះខាត

ថែមទៀតផង (McKenny and Tola, 2002)។

តារាងទី៣ បង្ហាញពីសកម្មភាពរកប្រាក់ចំណូល និងការប្រកបរបរចិញ្ចឹមជីវិតនៃគ្រួសារគំរូទាំងអស់ ដែលរៀបតាម លំដាប់ដូចជា ធ្វើនេសាទ កែច្នៃត្រី ទិញលក់ត្រី ចិញ្ចឹមត្រី កម្មករប្រចាំថ្ងៃ ការធ្វើជំនួញ និង ប្រមូលអុសជាដើម។ គួរអោយកត់សំគាល់យ៉ាងសំខាន់ថាសូម្បីតែ នៅក្នុងប្រភេទភូមិធ្វើស្រែសុទ្ធក៏មានចំនួនគ្រួសារដែលទទួលបានប្រាក់ចំណូលពី សកម្មភាពនេសាទ ស្មើរគ្នាដែរ។ ម្យ៉ាងវិញទៀត ភូមិទាំងនេះគឺមានភាពដូចគ្នាច្រើនបើ គិតអំពីប្រភពចំបងនៃការប្រកបរបរចិញ្ចឹមជីវិត ដូច្នេះហើយពួកគេងាយទទួលរងគ្រោះ ដោយថាហេតុ ដែលបណ្តាលពីការផ្លាស់ប្តូរនៃបរិស្ថាន (Keskinen, 2003) ។ ដោយលក្ខណៈនៃសហគមន៍នៅតំបន់បឹងទន្លេសាបមានមុខរបរ ច្រើនប្រភេទ ការគិតគូរអំពីការប្រកបរបរចិញ្ចឹមជីវិត ត្រូវតែយកចិត្តទុកដាក់ទៅលើការរស់នៅរបស់ប្រជាពលរដ្ឋ ដែលពឹងផ្អែកទៅលើផលផល និង ប្រពន្ធ័វារីអេកូឡូស៊ីទាំងស្រុង។

*គ្រួសារនៅជុំវិញបឹងទន្លេសាប ត្រូវបានបែងចែកដាច់ពីគ្នាទៅតាមប្រភេទនៃមុខរបរជាច្រើនរបស់ពួកគេ ។ នេះបង្ហាញអោយឃើញថាការគិតគូរនៃការប្រកបរបរចិញ្ចឹមជីវិតត្រូវតែយកចិត្តទុកដាក់ដល់ប្រជាជនដែលពឹងផ្អែកលើធនធានជលផល និង ប្រព័ន្ធវារិជាតទាំងស្រុង។*

ក្នុងន័យជាចរិតលក្ខណៈប្រជាសាស្ត្រនៃសហគមន៍នៅបឹងទន្លេសាប មានការសិក្សាជាច្រើនបានរាយការណ៍ថាចំនួនសមាជិកគ្រួសារជាមធ្យមគឺ ៦នាក់ ហើយមេគ្រួសារភាគច្រើនគឺជាបុរស ដែលមានប្រហែលពី ៦៥% ទៅ ៧០% នៃសមាជិកគ្រួសារទាំងនោះដែលមានអាយុអាចធ្វើការបាន និងមានចន្លោះពី ១១ ទៅ ៦០ឆ្នាំ (Ahmed *et al.*, 1998; Rab *et al.*, (2005); Israel *et al.*, (2005)។រីឯជនជាតិសំខាន់ៗនៃសមាជិកគ្រួសារ គឺមានខ្មែរ ចិន វៀតណាម និង ជនជាតិចាម មានភាគតិចជាងគេ។ ជាទូទៅ ការអប់រំ និង អក្ខរភាព មានអត្រាទាបនៅឡើយ ឧទាហរណ៍ មានចន្លោះពី



តារាងទី៣: ភាគរយនៃគ្រួសារដែលបានចូលរួមនៅក្នុងសកម្មភាពរកប្រាក់ចំណូលផ្សេងៗទៅតាមប្រភេទភូមិ

| | ខេត្តកំពង់ឆ្នាំង | | |
|---|---|---|---|
| ប្រភពនៃប្រាក់ចំណូល | នេសាទ | នេសាទផង និងធ្វើស្រែផង | ធ្វើស្រែ |
| នេសាទ | 100 | 89 | 80 |
| កែច្នៃត្រី | 48 | 19 | 2 |
| លក់ដូរត្រី | 22 | 28 | 3 |
| ចិញ្ចឹមត្រី | 10 | 7 | 3 |
| ផលិតឧបករណ៍នេសាទ | 2 | 2 | 0 |
| ធ្វើស្រែ | 31 | 69 | 78 |
| រកអុស | 46 | 51 | 52 |
| វែងព្រួល | 2 | 1 | 1 |
| ចិញ្ចឹមសត្វ | 30 | 24 | 28 |
| កម្មករ | 24 | 19 | 19 |
| មន្ត្រីរដ្ឋាភិបាល/បុគ្គលិកNGOs | 13 | 12 | 9 |
| អ្នកចងការប្រាក់ | 1 | 1 | 4 |
| ម៉ូតូឌុប/ឡាន/បើកបរទូក | 0 | 2 | 1 |
| លក់ដូរ | 20 | 19 | 30 |
| ផ្សេងៗ | 3 | 2 | 2 |

ប្រភពៈ ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005)

២០% ទៅ ២៥% នៃសមាជិកគ្រួសារដែលបានទទួលការអប់រំក្នុងប្រព័ន្ធ។ អ្នកដែលមាន ការអប់រំទាប គឺជាពិសេសមានចំពោះស្ត្រីជាមេគ្រួសារនិងជាសមាជិកគ្រួសារជាស្ត្រី។ ជាលទ្ធផល គ្រួសារដែលមានស្ត្រីជាមេគ្រួសារមានប្រាក់ចំណូល និង ស្ថានភាពសេដ្ឋកិច្ចសង្គមទាបជាងគ្រួសារដែលមានបុរសជាមេគ្រួសារ Rab *et al.*, (2005)។ នេះអាចសន្ទត់បានថាតាមការជាក់ស្តែងគ្រួសារនេសាទភាគច្រើនដែលរស់នៅក្នុងផ្ទះបណ្តែតទឹកមានលទ្ធភាពតិចតួចក្នុងការចូលសាលារៀន។

ដូចគ្នានឹងគ្រួសារភាគច្រើនទៅក្នុងតំបន់ជនបទដែរ គ្រួសាររស់នៅជុំវិញតំបន់បឹងទន្លេសាប មានលក្ខខ័ណ្ឌរស់នៅទាបនៅឡើយ។ ពួកគេមានលទ្ធភាពតិចតួចក្នុងការទទួលបាននូវតំរូវការចំបងដូចជា ទឹកសំរាប់ហូប និងសំរាប់ចំអិនអាហារ។ រីឯទ្រព្យសម្បត្តិកម្មសិទ្ធិនិងកំរិតបំណុលមានភាពខុសគ្នាទៅតាមប្រភេទគ្រួសារ។ ដោយហេតុថា គ្រួសារនេសាទមួយចំនួនសាងសង់ផ្ទះរបស់គេនៅលើទូក លើបែរត្រី និងសរសរឈើនៅក្នុងទឹកទន្ទឹមនឹងនោះដែរ ពួកគេមានកម្មសិទ្ធិដីធ្លីតិចតួចណាស់ ហើយផ្ទះរបស់ពួកគេមានតំលៃទាប បើប្រៀបធៀបទៅនឹងអ្នករស់នៅក្នុងភូមិធ្វើស្រែ ឧទាហរណ៍ ផ្ទៃដីកម្មសិទ្ធរបស់គ្រួសារនេសាទមានតែប្រហែលជា ២៥% នៃកម្មសិទ្ធរបស់គ្រួសារធ្វើស្រែតែប៉ុណ្ណោះ)។

គ្រួសារនេសាទទាំងនោះមានការចំណាយខ្ពស់ជាងគ្រួសារធ្វើស្រែ ដោយថាអាស្រ័យទៅតាមប្រភេទសំភារៈនិង ឧបករណ៍របស់ពួកគេ ឧទាហរណ៍ ដូចជាទូក និង ម៉ាស៊ីនសំរាប់នេសាទនិងធ្វើដំណើរ ម៉ាស៊ីនភ្លើងសំរាប់កែច្នៃត្រី និង ទូរស័ព្ទចល័តសំរាប់ទំនាក់ទំនង។ ដូច្នេះជារួមកំរិតនៃទ្រព្យសម្បត្តិរបស់គ្រួសារនេសាទគឺមានភាពខ្ពស់ជាងគ្រួសារធ្វើស្រែ ។ដូច្នេះហើយគ្រួសារនេសាទមានជាប់បំណុលច្រើនជាងគ្រួសារ រស់នៅក្នុងភូមិនេសាទផងនិងធ្វើស្រែផង និងធ្វើស្រែសុទ្ធ ព្រោះថាពួកគេមានការចំណាយច្រើនទៅលើសំភារៈប្រើប្រាស់និងគ្រឿងបរិភោគផ្សេងៗ។ ប្រភពនៃការខ្ចីប្រាក់ចំបងរបស់ពួកគេគឺ បងប្អូន មិត្តភក្តិ ឈ្មួញទិញលក់ ត្រី និង អ្នករកស៊ីចងការប្រាក់ក្នុងភូមិ ប៉ុន្តែមិនមែនជាស្ថាប័នហិរញ្ញវត្ថុទេ (Rab *et al.*, 2005) ។

*គ្រួសារអ្នកនេសាទ ហាក់ដូចជាមានភាគរយនៃការចំណាយលើការប្រើប្រាស់ផ្សេងៗខ្ពស់ជាងគេ បើប្រៀបធៀបទៅនឹងគ្រួសាររស់នៅក្នុងប្រភេទភូមិនេសាទផងនិងធ្វើស្រែផង និងប្រភេទភូមិធ្វើស្រែសុទ្ធ ។ ដូច្នេះអ្នកនេសាទ ភាគច្រើនជាប់បំណុល ដែលបានខ្ចី ភាគច្រើនពីបងប្អូន មិត្តភក្តិ អ្នកជំនួញ និង អ្នករកស៊ី ចងការប្រាក់ក្នុងភូមិ (ជាទូទៅមិនខ្ចីពីស្ថាប័ន ហិរញ្ញវត្ថុ)។*

## ៣. យុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិត និងការពឹងផ្អែកទៅលើធនធានធម្មជាតិ

ចំពោះពាក្យថា គ្រួសារ "ពឹងផ្អែកទៅលើធនធានជលផល" អាចត្រូវបានប្រើប្រាស់ជាទូទៅសំដៅទៅលើគ្រួសារភាគច្រើននៅជុំវិញបឹងទន្លេសាប។ វាត្រូវបានទទួលស្គាល់ថា កំរិតនៃការពឹងផ្អែកនេះប្រែប្រួលទៅតាមប្រភេទភូមិដោយសារទីតាំងរបស់វានៅជិតឬឆ្ងាយទឹកតែប៉ុណ្ណោះ។ ការកំណត់ជាប្រភេទភូមិ ដែលត្រូវបានប្រើនៅក្នុងរបាយការណ៍របស់ Rab *et al.* (2005) បានអោយដឹងថា "ភូមិនេសាទ" មានកំរិតនៃការពឹងផ្អែកទៅលើធនធានជលផលខ្ពស់ជាងគេ ហើយចំពោះ "ភូមិធ្វើស្រែស[១]" មានកំរិតពឹងផ្អែក នោះទាបបំផុត។ នេះបង្ហាញអោយឃើញច្បាស់អំពី ភាពខុសគ្នាក្នុងការប្រើប្រាស់ពេលវេលាសំរាប់ធ្វើនេសាទគឺ ៤.៤៥ ម៉ោងក្នុងមួយថ្ងៃ/គ្រួសារសំរាប់ភូមិនេសាទ និង ២.០៧ ម៉ោង សំរាប់គ្រួសារធ្វើស្រែនៅក្នុងរដូវបិទនេសាទ។ ចំពោះអ្នកដែលរស់នៅតាមមាត់ទឹកនិងក្នុងតំបន់ព្រៃលិចទឹកមានលទ្ធភាព ចូលទៅកន្លែងនេសាទប្រសើរជាងគេ ដូច្នេះពួកគេមាន ការពឹងផ្អែកខ្លាំងទៅលើការធ្វើនេសាទជាមួយគ្នានោះ ដែរអ្នកដែលមានដីធ្លីធ្វើកសិកម្មច្រើនគឺជាធម្មតាមាន ការចូលរួមច្រើនក្នុងការងារធ្វើសិកម្ម Ahmed *et al.*, (1998)។ ដូចគ្នានេះដែរ គ្រួសារដែលរស់នៅជិតដែនទឹកប្រហែលជា ៦ម៉ែត្រ

គឺមានការពឹងផ្អែកយ៉ាងខ្លាំង ទៅលើធនធានវារិជាតជាងអ្នកដែលរស់នៅឆ្ងាយពីដែនទឹកនិងនៅក្នុងទីរួមខេត្ត (Keskinen, 2003)។ លើសពីនេះទៅទៀត ការសិក្សាមួយ (ADB, 2004) ដែលប្រើប្រាស់គំរូនៃការកំនត់តំបន់របស់គំរោង ថាបណីជីវៈមណ្ឌលបឹងទន្លេសាប (Tonle Sap Biosphere Reserve Project) បង្ហាញថាប្រជាជន ដែលរស់នៅក្នុងតំបន់ស្នូល (Core zone) (ជាមួយនឹងមានកំរិតខ្ពស់នៃការការពារ) មានការពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានវារិជាត។ និងដូច្នេះហើយពួកគេមានការព្រួយបារម្ភច្រើនជាមួយនឹងការកកើតថ្មីនៃធនធានធម្មជាតិច្រើនជាងអ្នកដែលរស់នៅក្នុងតំបន់ទ្រទាប់ (Buffer zone) (តំបន់ដែលត្រូវបានរៀបចំឡើង សំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព) និងនៅក្នុងតំបន់អន្តរភាព (Transition zone) (តំបន់ដែលមានកំរិតសកម្មភាពសេដ្ឋកិច្ចខ្ពស់)។ ការសិក្សាចុងក្រោយនេះ ក៏បានបញ្ជាក់ផងដែរអំពីសារៈសំខាន់នៃកសិកម្មចំពោះ ប្រជាជនដែលរស់នៅតំបន់ស្នូលនិងតំបន់ទ្រទាប់។

*ភាគច្រើននៃគ្រួសាររស់តំបន់បឹងទន្លេសាប គឺជា "គ្រួសារដែលពឹងផ្អែកទៅលើការនេសាទ" ទោះបីជាកំរិតនៃការពឹងផ្អែកខុសគ្នាទៅតាមប្រភេទភូមិនីមួយៗក៏ដោយ ឧទាហរណ៍ ភូមិនេសាទផង និងធ្វើស្រែផង និង ភូមិធ្វើស្រែ និងដោយសារទីកន្លែង ឬភាពនៅជិតដែនទឹករបស់គេ។*

សកម្មភាពនៃការចិញ្ចឹមជីវិតនិងការរកប្រាក់ចំណូលផ្សេងៗគ្នា គឺជាយុទ្ធសាស្ត្រសំខាន់មួយនៃការចិញ្ចឹមជីវិតសំរាប់ប្រជាជនភាគច្រើនដែល រស់នៅជុំវិញបឹងទន្លេសាប ដោយឥតគិតអំពីមុខរបរចំបង ភេទ អាយុ និង ការអប់រំឡើយ។ សារៈសំខាន់នៃធនធានវារិជាតត្រូវបានសង្កត់ធន់ទៅពេលដែលគិត គួរពីសកម្មភាពដូចជាការប្រមូលវារីរុក្ខជាតិ សត្វព្រៃ និងសត្វមិនទៅក្នុងទឹក បក្សីទឹកនិងអុស ដែលធ្វើឡើង ជាប្រចាំថ្ងៃដើម្បីបំពេញតំរូវការចាំបាច់របស់សហគមន៍ ជនបទទាំងនោះ។ ឧទាហរណ៍ គ្រួសារទាំងអស់ដែលប្រមូលអុសសំរាប់ដុត និងកែច្នៃត្រី និងមានភាគច្រើននៃគ្រួសារជាច្រើនដែលពឹងផ្អែកទៅលើការបេះត្រកួនត្រួយរាំង និងព្រលិតសំរាប់ប្រើប្រាស់នៅក្នុងផ្ទះ។ សកម្មភាពទាំងពីរនេះ ក៏ដូចជាការប្រើប្រាស់ទន្លេសំរាប់ធ្វើដំណើរ ត្រូវបានចាត់ទុកថាមានសារៈសំខាន់ណាស់ចំពោះគ្រួសារគំរូនៅក្នុងការសិក្សារបស់ Rab *et al.* (2005) (តារាងទី៤)។ ដូច្នេះ សិទ្ធ និងការប្រើប្រាស់ធនធានធម្មជាតិជាសាធារណៈ គឺជាកត្តាសំខាន់ក្នុងការទ្រទ្រង់ការចិញ្ចឹមជីវិត ជាពិសេស ការចិញ្ចឹមជីវិតរបស់ប្រជាជនដែលមានជំរើសតិចតួច ឬ អ្នកដែលគ្មានជំរើសផ្សេងៗទៀត។ និន្នាការធ្លាក់ចុះនៃលទ្ធភាព និង ភាពដែលងាយរកបាននៃផលិតផល និង ផលប្រយោជន៍ផ្សេងៗដែលទាញយកពីធនធានធម្មជាតិជាសាធារណៈ ជាពិសេស ព្រៃលិចទឹក ទន្លេ និងបឹងបួរធំៗ ត្រូវបានបង្ហាញនៅក្នុងការសិក្សានាឆ្នាំ១៩៩៥ (Ahmed *et al.*, 1998) និងការសិក្សាថ្មីៗនេះ (Keskinen, 2003)។ បន្ថែមពីលើការនេសាទហួសកំរិតដែលមានភាពប៉ះពាល់ដោយផ្ទាល់ទៅលើការប្រកបរបរនេសាទនោះមានមូលហេតុមួយចំនួនផ្សេងទៀតដែលបណ្តាលឱ្យមាននិន្នាការនេះ គឺរួមមានការផ្លាស់ប្តូរស្ថានភាពបរិស្ថាន កំនើន ប្រជាជន និង ការបំផ្លាញជំរកត្រី (Keskinen, 2003)។

*ភាពខុសគ្នានៃសកម្មភាពរកប្រាក់ចំណូល និង សកម្មភាពរកទទួលទាន គឺជាយុទ្ធសាស្ត្រនៃរបរចិញ្ចឹមជីវិតដ៏សំខាន់របស់ប្រជាជនភាគច្រើនដែលរស់នៅជុំវិញបឹងទន្លេសាប ដោយឥតគិតអំពីមុខរបរចំបង ភេទ អាយុ និង ការអប់រំ។*

តារាងទី៤: សារៈសំខាន់នៃធនធានធម្មជាតិជាសាធារណៈដោយផ្អែកលើរបាយការណ៍នៃការប្រើប្រាស់តាមរយៈ ការអង្កេតគ្រួសារនៅខេត្តកំពង់ឆ្នាំង និង សៀមរាប

| កំរិតនៃសារៈសំខាន់ | % នៃគ្រួសារដែលប្រើប្រាស់ធនធាន | ធនធានធម្មជាតិជាសាធារណៈ |
|---|---|---|
| ខ្ពស់បំផុត | >80 | អុស ត្រកួន |
| ខ្ពស់ | >60 | ត្រយរាំង ប្រលិត ផ្កាស្មោរ |
| មធ្យម | >30 | សណ្តាន់ ការធ្វើដំណើរ កណ្តុរ ត្រី ក្តាម/ខ្យង ឈូក ក្រអៅឈូក |
| ទាប | >10 | កំប្លោក ត្រយសណ្តាន់ កន្ទួត ចិញ្ចឹមសត្វ អន្ទង់ ឱសថបុរាណ កន្លែងកំសាន្ត ពស់ កន្ទ្រប |
| ទាបបំផុត | <10 | សត្វព្រៃ/បក្សី សាវម៉ាវព្រៃ ឬស្សី ចិញ្ចឹមទា និង អណ្តើក |

ប្រភពៈ ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005) ចំនួនសរុបនៃគ្រួសារអង្កេតគឺ ២៧០

*សិទ្ធិ និងការប្រើប្រាស់ធនធានធម្មជាតិជាសាធារណៈ គឺជាកត្តាមួយសំខាន់ដល់ការទ្រទ្រង់ក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជន ជាពិសេសចំពោះអ្នកដែលមានជំរើសតិចតួចក្នុងការប្រកបរបរចិញ្ចឹមជីវិត។*

តួនាទីយេនឌ័រតាមប្រពៃណី មានការទាក់ទងជាមួយយុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិត។ ស្ត្រីនៅតែមានភារកិច្ចទទួលខុសត្រូវចំបងទៅលើកិច្ចការផ្ទះនិងការងារថែទាំកូនចៅ ទោះបីជាពួកគេជាអ្នករកម្ហូបអាហារ បន្លែ និង ធនធាន ធម្មជាតិផ្សេងៗទៀតសំរាប់ប្រើប្រាស់ក្នុងផ្ទះក៏ដោយ។ ម្យ៉ាងវិញទៀត បុរសតែងតែធ្វើការនៅក្រៅផ្ទះដើម្បីរកប្រាក់ចំណូល រួមមានការធ្វើនេសាទឬការធ្វើស្រែ ឬក៏ធ្វើ ទាំងពីរមុខ។ ជាធម្មតា ស្ត្រីមិនចូលរួមដោយផ្ទាល់ក្នុងការធ្វើនេសាទទេ ប៉ុន្តែពួកគេមានតួនាទីសំខាន់នៅក្នុងការផ្គត់ផ្គង់ផលិតផលវារិជាត វារីវប្បកម្ម និងការថែរក្សា និង ជួសជុលឧបករណ៍នេសាទ (Israel *et al.*, 2005; McKenney and Tola, 2002; Keskinen, 2003)។ ការបែងចែកសកម្មភាពយេនឌ័រតាមលក្ខណៈប្រពៃណី គឺមិនអាចកើតឡើងក្នុងគ្រួសារដែលមានស្ត្រីជាមេគ្រួសារឡើយ ទន្ទឹមនឹងនោះដែរ បើប្រៀបធៀបទៅនឹងចំនួនស្ត្រីជាមេគ្រួសារបានរាយការណ៍ថា មានមុខរបរចំបងដូចគ្នាទៅនិងមេគ្រួសារជាបុរសដែរ (តារាងទី៥)។ គេបានសង្កេតឃើញថា ចំពោះស្ត្រី នៅពេលដែលគេមានភាពចាំបាច់និងឱកាសហុចអោយ ពួកគេទៅ



តារាងទី៥: ការបែងចែកជាភាគរយនៃមេគ្រួសារជាបុរស និងស្ត្រី តាមរយៈមុខរបរ និងប្រភេទភូមិ

| ប្រភេទមុខរបរ | នេសាទ | | នេសាទផងនិងធ្វើស្រែផង | | ធ្វើស្រែ | |
|---|---|---|---|---|---|---|
| | បុរស | នារី | បុរស | នារី | បុរស | នារី |
| នេសាទ | 82 | 89 | 68 | 70 | 12 | 8 |
| កែច្នៃត្រី | - | - | 3 | - | - | - |
| លក់ដូរត្រី | 3 | - | 1 | - | - | - |
| ចិញ្ចឹមត្រី | 9 | - | - | - | - | - |
| កម្មករ | 5 | 5 | 24 | 30 | 86 | 92 |
| មន្ត្រីរដ្ឋាភិបាល/ បុគ្គលិកNGOs | - | - | 1 | - | - | - |
| គ្រូបង្រៀន | 1 | 5 | 1 | - | 3 | - |
| ផ្សេងៗ | - | - | 1 | - | - | - |

ប្រភពៈ ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005)

ធ្វើនេសាទនៅតាមស្ទឹង ឬ ទន្លេដោយប្រើប្រាស់ឧបករណ៍ មងតូចៗ ហើយជាញឹកញាប់គឺទៅជាមួយកូនរបស់គេ។ ម្យ៉ាងវិញទៀតការចូលរួមរបស់ស្ត្រីក្នុងការធ្វើនេសាទ អាចមានច្រើនជាងពីការពិតជាក់ស្តែងដែលត្រូវបានទទួលស្គាល់ដោយសង្គម ព្រោះភាគច្រើននៃសកម្មភាពរបស់ ពួកគេដើម្បីផ្គត់ផ្គង់តំរូវការនៅក្នុងផ្ទះតែប៉ុណ្ណោះ ដោយ "គ្មានការទទួលស្គាល់ ឬ មើលឃើញឡើយ"។

*ការចូលរួមរបស់ស្ត្រីក្នុងការធ្វើនេសាទ អាចមានច្រើនជាងពីការពិតជាក់ស្តែងដែលត្រូវបានទទួលស្គាល់ពីមុន ព្រោះភាគច្រើននៃសកម្មភាពរបស់ពួកគេគឺដើម្បីផ្គត់ផ្គង់នូវតំរូវការនៅក្នុងផ្ទះតែប៉ុណ្ណោះដោយ "គ្មានការទទួលស្គាល់ ឬ មើលឃើញឡើយ"។*

**តើការនេសាទគឺជារបៀបរស់នៅមួយដែលគេចូលចិត្ត ឬ ក៏ជាជំរើសតែមួយគត់នៃការប្រកបរបរចិញ្ចឹមជីវិត?** ការសិក្សារបស់ Ahmed *et al.*, (1998) បានបង្ហាញថាហេតុផលចំបងនៃការចូលរួមរបស់ប្រជាជនក្នុងការធ្វើនេសាទ គឺជាទំលាប់ឬកេរ្តិ៍តំណែលពីគ្រួសាររបស់គេ ហើយក៏ជាផ្នែកមួយនៃការរកម្ហូបអាហារ មួយតាមបែបបុរាណសំរាប់ប្រើប្រាស់ក្នុងផ្ទះ និងផ្តល់ជាប្រភពនៃម្ហូបអាហារដែលមានតំលៃទាប។ យោងទៅតាម Keskinen (2003) មានជាង ៦០% នៃគ្រួសារគំរូដែលរស់នៅឆ្ងាយពីបឹងទន្លេសាប អាចមានភាពងាយនឹងផ្លាស់ប្តូរពីការធ្វើនេសាទទៅមុខរបរផ្សេងទៀតជាច្រើន ហើយចំពោះអ្នកដែលរស់នៅជិតដែនទឹកវិញមានលទ្ធភាពតិចតួចបំផុតក្នុងការផ្លាស់ប្តូរមុខរបរ។ គេសង្កេតឃើញថាមានគ្រួសារប្រហែលពី ៤០ទៅ៦០% ដែលរស់នៅជុំវិញបឹងទន្លេសាប រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ (Poverty line) (ADB, 2005)។ វាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការទទួលស្គាល់អំពីភាពចាំបាច់នៃការចិញ្ចឹមជីវិតផ្សេងៗ និងឱកាសរកការងារ ផ្សេងទៀតនៅក្រៅវិស័យជលផល។

## ៤. តំលៃនៃធនធានជលផលនិងធនធានវារិជាត

ព័ត៌មានស្តីអំពីតំលៃនៃធនធានជលផលនិងវារិជាតគឺមានសារៈប្រយោជន៍ក្នុងការកំនត់នូវវិសាលភាពរបស់ធនធានទាំងនោះដែលបានចូលរួមទៅក្នុងសុខមាលភាពសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេស ព្រមទាំងដើម្បីទ្រទ្រង់នូវការប្រកបរបរចិញ្ចឹមជីវិតនៅតាមជនបទ ជាពិសេសនៅកន្លែងដែលមានការពឹងផ្អែកទៅលើធនធានទាំងនោះខ្ពស់ ក៏ដូចជានៅក្នុងករណីសហគមន៍នានានៅជុំវិញបឹងទន្លេសាប។ "តំលៃសរុប" នៃប្រព័ន្ធវារីអេកូឡូស៊ីអាចត្រូវបានគិតគូរតាមរយៈតំលៃប្រើប្រាស់ និង តំលៃមិនប្រើប្រាស់ (Use and Non-use values) (រូបភាពទី១)។ ក្នុង ចំណោមតំលៃប្រើប្រាស់ គឺរួមមានតំលៃប្រើប្រាស់ដោយផ្ទាល់ (Direct Use values) តំលៃប្រើប្រាស់ដោយប្រយោល (Indirect Use values) និង តំលៃនៃការជ្រើសរើស (Option Values)។ តម្លៃ "ប្រើប្រាស់ដោយផ្ទាល់" ទាំងនោះគឺត្រូវទទួលបានពីផលិតផល ការប្រើប្រាស់ និងការលក់ធនធានទាំងនោះ ដូចជាតាមរយៈធ្វើនេសាទ ធ្វើស្រែឬកសិកម្ម ការប្រមូលអុសហើយព្រមទាំងការប្រើប្រាស់ដែលមិនមែនជាម្ហូបអាហារ ដូចជា ថាមពល លំនៅដ្ឋានគមនាគមន៍ និងកន្លែងលំហែរកាយ។ "តំលៃប្រើប្រាស់ដោយប្រយោល" គឺជាតំលៃដែលទទួលបានមកពីតួនាទីនៃប្រព័ន្ធអេកូឡូស៊ី និង សេវាកម្មផ្សេងៗទៀតដែលផ្តល់ដោយប្រព័ន្ធធនធានវារិជាត ឧទាហរណ៍ ដូចជាការ ប្រើប្រាស់ព្រៃលិចទឹកដើម្បីជាជំរកត្រីពងកូននិងជាចំណីសត្វ ការរក្សាគុណភាពទឹក ការស្តុកនិងលំហូរនៃទឹក ការគ្រប់គ្រងទឹកជំនន់និងការពារខ្យល់ព្យុះ ការរក្សាជាម្ហូបអាហារ និង រក្សាឱ្យមានលំនឹងមីក្រូអាកាសធាតុ។ "តំលៃនៃការជ្រើសរើស" គឺបានមកពីការការពារដើម្បី ការប្រើប្រាស់ធនធានសំរាប់ពេលអនាគត ឧទាហរណ៍ ដូចជាការបង្កើតតំបន់ការពារមួយនៅក្បែរកន្លែងនោះ។ មានប្រភេទនៃតំលៃផ្សេងៗទៀតដូចជា "តំលៃមិនប្រើប្រាស់" គឺសំដៅទៅលើ "តំលៃមានស្រាប់" ដែលទទួលបានមកពីចំណេះដឹងនិងសេចក្តី




រូបភាពទី ១: ប្រភេទផ្សេងៗនៃតំលៃដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធអេកូឡូស៊ីរបស់ធនធានវារិជាតិ នៅតំបន់បឹងទន្លេសាប

សប្បាយរីករាយដែលផ្សារ ភ្ជាប់ជាមួយនឹងការយល់ដឹងពីស្ថានភាពធនធានធម្មជាតិដោយភាពមានលក្ខណៈល្អប្រសើរ និង "តំលៃជាកេរ្តិ៍" ដែលផ្សារភ្ជាប់ជាមួយនឹងការពេញចិត្ត ដើម្បីបង្កើតឡើងនូវធនធានឱ្យមានភាពប្រសើរឡើងសំរាប់មនុស្ស ជំនាន់ក្រោយទៀត។ ម្យ៉ាងវិញទៀត តំលៃមិនប្រើ ប្រាស់ទាំងនោះ គឺពិបាកមើលឃើញ និងធ្វើការប៉ាន់ស្មានជាងតំលៃប្រើប្រាស់ ដូច្នេះហើយទើបគេមិនសូវយកមកពិនិត្យ និង ពិចារណាក្នុងការងារសំរេចចិត្តនៃការគ្រប់គ្រងទេ។ ជាក់ស្តែងការវាយតំលៃនៃធនធានធម្មជាតិ ជាញឹកញាប់គឺសំដៅទៅលើតំលៃប្រើប្រាស់ ដោយផ្ទាល់ ដែលជាការងារមួយចំពោះមុខដែលមាន រួចមកហើយ ដោយគិតថា "តំលៃសរុបពិត" ហាក់បី ដូចជាមានភាពខ្ពស់ជាងតំលៃប៉ាន់ស្មាន ឧទាហរណ៍ (សូមអាន *Ratner et al.* (2004), តំលៃនៃ តំបន់ដីសើម)។ ជាទូទៅគេចូលចិត្តប៉ាន់ស្មានតំលៃទាំង នោះជា "ឯកតាដុល្លារ" ហើយផលវិបាកនៃការវាយតំលៃធនធានធម្មជាតិធ្វើ អោយគេសន្និដ្ឋានថា ការវាយតំលៃនៃធនធានទាំងនោះ គឺតាមរយៈការប្រើប្រាស់ធនធាន និង លទ្ធភាពនិងសារៈសំខាន់របស់វាចំពោះការប្រកបរបរចិញ្ចឹមជីវិតក្នុងតំបន់នោះ។

វិធីសាស្ត្រមួយដើម្បីទទួលបាននូវ "តំលៃសេដ្ឋកិច្ចពិត" (Net Economic Value, (NEV) នៃធនធានជលផល ធនធានវារិជាតិ និង ធនធានធម្មជាតិជាសាធារណៈផ្សេងៗទៀត គឺតាមរយៈការប៉ាន់ស្មានចំណូល សរុបបានមកពីការប្រមូលផលិតផល និងលក់ផលិតផលទាំងនោះ។ ដូច្នេះថ្លៃដើមសរុបនៃផលិតផលត្រូវបានដកចេញពីចំណូលសរុប។ ចំណែកឯ វិធីសាស្ត្រមួយផ្សេងទៀត គឺការប៉ាន់ស្មានតម្លៃដោយប្រយោលតាមរយៈយកព័ត៌មាននៃចំណូល "សរុបដុល (Gross)" របស់គ្រួសារដែលបានមកពីសកម្មភាពផ្សេងៗគ្នា។ នៅពេលដែលប្រើប្រាស់ ទិន្នន័យនេះតែមួយគត់នោះ គឺមិនអាចចង្អុលបង្ហាញអំពីតំលៃសរុបនៃធនធានទេ វាគ្រាន់តែឆ្លុះបញ្ចាំងពីសារៈសំខាន់នៃធនធានទាំងនោះ តាមរយៈប្រាក់ចំណូលដែលបានមកពីធនធាននោះតែប៉ុណ្ណោះ។ នៅក្នុងករណីសិក្សាមួយស្តីពីសហគមន៍ជនបទដែលចូលរួមក្នុងសកម្មភាពនេសាទសំរាប់ហូបឬនេសាទគ្រួសារ និង នេសាទសិប្បកម្ម ការប៉ាន់ស្មាននៃតំលៃទាំងពីនេះ ហាក់ដូចជាមានភាព ប្រហាក់ប្រហែលគ្នា ជាពិសេសនៅពេលដែលសួរអំពី ប្រាក់ចំណូលដែលបានមកពីសកម្មភាពផ្សេងៗ អ្នកឆ្លើយនូវសំនួរទាំងនោះតែងតែគិតជាដំបូងអំពីចំនួន ប្រាក់ដែលគេបានមកពីការផលិត និង តម្លៃទឹកប្រាក់ដែលគេទទួលបាន។

ដូចនៅក្នុងការគណនាពីតំលៃសេដ្ឋកិច្ចពិត (NEV) ព័ត៌មានថ្លៃដើមគឺចាំបាច់ត្រូវតែគិតដើម្បីប្តូរពីចំណូលសរុបដុលទៅជាចំណូលពិត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានទាំងនោះ ជាធម្មតាមានការពិបាកនឹងទទួលបាននូវតម្លៃពិតណាស់។

ដោយប្រើប្រាស់ទិន្នន័យដែលដកស្រង់ចេញពីការធ្វើអង្កេតពីគ្រួសារដែលបានធ្វើឡើងដោយ Rab *et al.* (2005) តំលៃប្រើប្រាស់ផ្ទាល់នៃធនធានជលផល និងធនធានវារិជាតនៅតំបន់បឹងទន្លេសាបត្រូវបានប៉ាន់ស្មានដោយផ្អែកទៅលើប្រាក់ចំណូលប្រចាំឆ្នាំនៃគ្រួសារដែលបានមកពីគ្រប់ប្រភពធនធានទាំងអស់នោះ។ ការប៉ាន់ស្មានប្រាក់ចំណូលប្រចាំគ្រួសារនិមួយៗត្រូវបានចាត់ទៅតាម "កំរិត" នៃចំណូល (ឬការបែងចែកតាមទ្រព្យសម្បត្តិ) ដើម្បីបែងចែកនូវភាពខុសៗគ្នាអំពីទំហំ និងកំរិតនៃសកម្មភាព (តារាងទី៦)។ ភាពខុសគ្នានៃចំណូលប្រចាំឆ្នាំជាមធ្យមក្នុងគ្រួសារនិមួយៗ រវាងអ្នកដែលមានកំរិតចំណូលខ្ពស់ជាងគេ និង អ្នកដែលមានកំរិតចំណូលទាបបំផុត គឺមានទំហំខុសគ្នាខ្លាំងណាស់ ប៉ុន្តែគំលាតនោះជាពិសេសមានគម្លាតធំនៅក្នុងប្រភេទភូមិនេសាទ។ លើសពីនេះទៅទៀត ប្រាក់ចំណូលតាមគ្រួសារនិមួយៗ គឺមានភាពខុសគ្នាតិចតួចបំផុតរវាងប្រភេទភូមិនិងខេត្តខ្លះៗឧទាហរណ៍ចំពោះ គ្រួសារនៅក្នុងភូមិនេសាទដែលមានកំរិតចំណូលទាប ជាងគេបំផុត និងចំពោះគ្រួសារនៅក្នុងគ្រប់ប្រភេទភូមិទាំងអស់នៅក្នុងខេត្តកំពង់ឆ្នាំង មានចំណូលទាបជាងគ្រួសារនៅក្នុងខេត្តសៀមរាប។ ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី២ ភាគច្រើននៃគ្រួសារនៅក្នុងខេត្តទាំងពីរនោះ ជាពិសេសនៅក្នុងខេត្តកំពង់ឆ្នាំងរកប្រាក់ចំណូលបានតិចជាង ១.០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ នៅក្នុងករណីទាំងពីរនេះ មានគ្រួសារភាគច្រើននៅក្នុងប្រភេទភូមិធ្វើស្រែសុទ្ធ មានកំរិតចំណូលទាបជាងគ្រួសារនៅក្នុងភូមិនេសាទសុទ្ធ។

"តំលៃប្រើប្រាស់ដោយផ្ទាល់" បានរៀបរាប់នៅក្នុងតារាងទី៦ គឺផ្អែកទៅលើចំណូលនៃគ្រួសារនិមួយៗ។ ដំណើរការនៃការប៉ាន់ស្មានមួយត្រូវបានប្រើប្រាស់ដើម្បីគណនាតំលៃប្រើប្រាស់ដោយផ្ទាល់សរុប សំរាប់គ្រួសារទាំងអស់ "ដែលពឹងផ្អែកទៅលើធនធានវារិជាត" នៅក្នុងខេត្តទាំងប្រាំ។ ពាក្យខាងលើត្រូវបានប្រើនៅទីនេះ គឺដើម្បី ស្វែងយល់ពីសារៈសំខាន់យ៉ាងទូលំទូលាយនៃបឹងទន្លេសាប ស្តីពីផលប្រយោជន៍ដោយផ្ទាល់ពីការ



តារាងទី៦: ការប៉ាន់ស្មានប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារ (ជាដុល្លារ) ពីប្រភពទាំងអស់ តាមប្រភេទកំរិតប្រាក់ចំនូល តាមប្រភេទភូមិ និង តាមខេត្ត

| | ចំណូលប្រចាំឆ្នាំជាមធ្យមក្នុងមួយគ្រួសារ (គិតជាដុល្លារអាមេរិក) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ខេត្តកំពង់ឆ្នាំង | | | ខេត្តសៀមរាប | | | ទាំងពីរខេត្ត | | |
| កំរិតចំណូល | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ |
| ≤ 1,000 | 412 | 414 | 406 | 655 | 580 | 432 | 533 | 466 | 418 |
| 1,001 – 2,000 | 1,254 | 1,221 | 1,296 | 1,320 | 1,322 | 1,451 | 1,289 | 1,302 | 1,398 |
| 2,001 – 5,000 | 2,548 | | | 3,655 | 3,345 | 3,525 | 2,991 | 3,345 | 3,525 |
| > 5,000 | 6,448 | | | 9,617 | 5,445 | | 8,349 | 5,445 | |

| | ចំនួននៃគ្រួសារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ខេត្តកំពង់ឆ្នាំង | | | ខេត្តសៀមរាប | | | ទាំងពីរខេត្ត | | |
| កំរិតចំណូល | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ |
| ≤ 1,000 | 26 | 42 | 42 | 26 | 19 | 37 | 52 | 61 | 79 |
| 1,001 – 2,000 | 11 | 3 | 3 | 12 | 12 | 4 | 23 | 15 | 7 |
| 2,001 – 5,000 | 6 | | | 4 | 11 | 4 | 10 | 11 | 4 |
| > 5,000 | 2 | | | 3 | 2 | | 5 | 2 | |
| | 45 | 45 | 45 | 45 | 44* | 45 | 90 | 89 | 90 |

*គ្រួសារតំរូមួយខុសឆ្ងាយពីគេត្រូវដកចេញ

ប្រភព: ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005)




រូបភាពទី ២: *ភាគរយនៃការបែងចែកគ្រួសារ តាមកម្រិតប្រាក់ចំណូលសំរាប់ប្រភេទភូមិនិមួយៗ*

នេសាទ។ វាគួរអោយកត់សំគាល់ផងដែរថា ការប៉ាន់ស្មានទាំងនេះគឺជាតំលៃអប្បបរមាតែប៉ុណ្ណោះ (ឬក៏នៅក្នុងចន្លោះចំណូលទាបបំផុត) ដោយគិតថាសមាមាត្រដ៏ល្អមួយនៃផលិតផលដែលបានមកពីសកម្មភាពផ្សេងៗ គឺសំរាប់តែការប្រើប្រាស់ក្នុងផ្ទះ។ ការផ្តល់យោបល់មួយចំនួនស្តីពី របៀបកែសំរួលលើការប៉ាន់ស្មានទាំងនោះត្រូវបានលើក យកមកពិភាក្សានៅខាងក្រោម។

ជាដំបូង ចំនួនគ្រួសារនៅក្នុងខេត្តនិមួយៗ គឺបានមកពីការធ្វើជំរឿននៅឆ្នាំ ២០០២ (UNDP, 2003) ហើយនឹងសមាមាត្រនៃគ្រួសារដែលពឹងផ្អែកទៅលើធនធានវារិជាតនៅក្នុងខេត្តនិមួយៗ ដែលបានយកពីរបាយការណ៍របស់ Ahmed *et al.* (1998)។ ជាមធ្យមប្រហែលជា ៤២% នៃឃុំនៅក្នុងខេត្តទាំងប្រាំត្រូវបានចាត់ទុកថាជាឃុំ "នេសាទ" ដែលនៅក្នុងចន្លោះនៅក្នុងខេត្តកំពង់ឆ្នាំង មានភាគរយខ្ពស់ជាងគេ (៥៥%) និងនៅក្នុងខេត្តសៀមរាបមានភាគរយទាបជាងគេ (៣១%)។ ដោយប្រើប្រាស់សមាមាត្រទាំងនោះ ចំនួនប្រជាជនសរុបដែលពឹងផ្អែកទៅលើធនធានវារិជាតនៃបឹងទន្លេសាប គឺត្រូវបានប៉ាន់ស្មានថាប្រហែលជា ១.២៥លាននាក់ (ដោយចាត់ទុកថាចំនួនសមាជិកគ្រួសារជាមធ្យមគឺ ៦នាក់) ហើយទន្ទឹមនឹងនោះដែរគេសន្មត់ថា អត្រាកំណើនប្រជាជនមានប្រហែលជា ២% បើធៀបទៅនឹងឆ្នាំ ១៩៩៥ ដែលបានរាយការណ៍ក្នុងរបាយការណ៍ Ahmed *et al.* (1998)។ ចំណូលជាមធ្យមរបស់គ្រួសារនិមួយៗ នៅក្នុងខេត្តទាំងពីរ (គឺតាមប្រភេទចំណូល) ត្រូវបានប្រើប្រាស់ដើម្បីធ្វើការប៉ាន់ស្មានប្រាក់ចំណូលសំរាប់ខេត្តបីផ្សេងៗទៀត ដោយឧបមាថាការប៉ាន់ស្មាននៅក្នុង ខេត្តកំពង់ឆ្នាំង តំណាងអោយគ្រួសារនៅក្នុងចន្លោះចំណូលទាប ចំពោះការប៉ាន់ស្មាននៅក្នុងខេត្តសៀមរាប តំណាងអោយគ្រួសារនៅក្នុងចន្លោះចំណូលខ្ពស់ (តារាងទី៦)។ កត់សំគាល់ផងដែរថា ដើម្បីអោយមាន ភាពងាយស្រួល ចំណូលត្រូវគិតជាមធ្យម សំរាប់ប្រភេទ ភូមិទាំងអស់។ តារាងទី៧ បង្ហាញថាការគណនាចំណូល ប្រចាំឆ្នាំសរុប "ដុល" សំរាប់គ្រួសារដែលពឹងផ្អែកទៅលើធនធានវារិជាតសំរាប់ខេត្តទាំងប្រាំដែលរស់នៅជុំវិញបឹងទន្លេសាប។ ការប៉ាន់ស្មានសំរាប់ខេត្តបីផ្សេង ទៀត (បាត់ដំបង ពោធិសាត់ និង កំពង់ធំ) គឺផ្អែកទៅលើតំលៃ

តារាងទី៧: ប្រាក់ចំណូល "ដុល" សរុបសំរាប់គ្រួសារដែលផ្អែកលើប្រភពធនធានវារិជាតនៃបឹងទន្លេសាប

ក) ប្រាក់ចំនូលជាមធ្យមប្រចាំឆ្នាំតាមគ្រួសារ (ដុល្លារអាមេរិក)

| កំរិតចំណូល | ខេត្តកំពង់ឆ្នាំង | ខេត្តសៀមរាប | ទាំងពីរខេត្ត |
|---|---|---|---|
| ≤ 1,000 | 409 | 556 | 470 |
| 1,001 – 2,000 | 1,229 | 1,364 | 1,321 |
| 2,001 – 5,000 | 2,548 | 3,508 | 3,287 |
| > 5,000 | 6,448 | 7,531 | 6,897 |

ខ) ការបែងចែកជាភាគរយនៃគ្រួសារតាមកំរិតប្រាក់ចំណូល

| កំរិតចំណូល | ខេត្តកំពង់ឆ្នាំង | ខេត្តសៀមរាប | ទាំងពីរខេត្ត |
|---|---|---|---|
| ≤ 1,000 | 83 | 61 | 72 |
| 1,001 – 2,000 | 12 | 21 | 16 |
| 2,001 – 5,000 | 4 | 14 | 9 |
| > 5,000 | 1 | 4 | 3 |

គ) ប៉ាន់ស្មានចំនួនគ្រួសារដែលពឹងផ្អែកលើប្រភពធនធានវារិជាត

| កំរិតចំណូល | ខេត្តកំពង់ឆ្នាំង | ខេត្តសៀមរាប | ខេត្តបាត់ដំបង | ខេត្តពោធិ៍សាត់ | ខេត្តកំពង់ធំ | សរុប |
|---|---|---|---|---|---|---|
| ≤ 1,000 | 39,742 | 24,630 | 32,384 | 27,309 | 26,924 | 150,988 |
| 1,001 – 2,000 | 5,746 | 8,479 | 7,196 | 6,069 | 5,983 | 33,473 |
| 2,001 – 5,000 | 1,915 | 5,653 | 4,048 | 3,414 | 3,365 | 18,395 |
| > 5,000 | 479 | 1,615 | 1,349 | 1,138 | 1,122 | 5,703 |
| សរុប | 47,882 | 40,376 | 44,978 | 37,929 | 37,394 | 208,560 |

ឃ) ប៉ាន់ស្មានចំណូល "ដុល" សំរាប់គ្រួសារទាំងអស់តាមប្រភេទភូមិ លានដុល្លារអាមេរិក)

| កំរិតចំណូល | ខេត្តកំពង់ឆ្នាំង | ខេត្តសៀមរាប | ខេត្តបាត់ដំបង | ខេត្តពោធិ៍សាត់ | ខេត្តកំពង់ធំ | សរុប |
|---|---|---|---|---|---|---|
| ≤ 1,000 | 16.2 | 13.7 | 15.2 | 12.8 | 12.7 | 70.6 |
| 1,001 – 2,000 | 7.1 | 11.6 | 9.5 | 8.0 | 7.9 | 44.1 |
| 2,001 – 5,000 | 4.9 | 19.8 | 13.3 | 11.2 | 11.1 | 60.3 |
| > 5,000 | 3.1 | 12.2 | 9.3 | 7.8 | 7.7 | 40.1 |
| សរុប | 31.3 | 57.2 | 47.3 | 39.9 | 39.4 | 215.1 |

ប្រភព: ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005)

មធ្យមរវាងខេត្តកំពង់ឆ្នាំង និង សៀមរាប។

ជាទូទៅ មានចំនួន ២១៥លានដុល្លារអាមេរិក ត្រូវបានប៉ាន់ស្មានថាជាចំណូលប្រចាំឆ្នាំសរុប ឬ ដុល សំរាប់សហគមន៍ទាំងនោះ ដោយបង្ហាញពី "សមាមាត្រមួយ" នៃតំលៃប្រើប្រាស់ដោយផ្ទាល់ និង សារៈសំខាន់នៃធនធានវារិជាតរបស់សហគមន៍នៅជុំវិញបឹងទន្លេសាប។ នេះបង្ហាញអោយឃើញថា ប្រាក់ចំណូលប្រចាំឆ្នាំក្នុងម្នាក់ ប្រហែលជា ១៧២ ដុល្លារអាមេរិក ដោយផ្អែកទៅលើចំនួនប៉ាន់ស្មានលើប្រជាជនប្រហែលជា ២០៥.០០០ គ្រួសារ ដែលមានសមាជិកគ្រួសារជាមធ្យមប្រហែល ៦នាក់។ នៅពេលដែលគិតអំពីចំណូលនៃគ្រួសារទៅតាមកំរិតប្រាក់ចំណូល ស្ថានភាពនៃគ្រួសារភាគច្រើនមានភាពច្បាស់លាស់ ដូចជាមានជាង ៧០% នៃគ្រួសារសរុបរកប្រាក់ចំណូលបានត្រឹមតែ ៤៧០ដុល្លារអាមេរិក តែប៉ុណ្ណោះ ឬប្រហែលជា ៧៨ដុល្លារអាមេរិកក្នុងម្នាក់១ (រូបភាពទី៣)។ ផ្ទុយទៅវិញ មានប្រហែលជា ១២% នៃគ្រួសារតិចតួច (ដែលមានប្រាក់ចំណូលលើសពី ២.០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ) ដែលមានជិតពាក់កណ្តាលនៃចំណូលសរុបដុលនៃគ្រួសារទាំងអស់។ គ្រួសារដែលមានប្រាក់ចំណូល ជាមធ្យមតិចជាង ១.០០០ដុល្លារអាមេរិក គឺទំនងជាអ្នកនេសាទគ្រួសារ ឬ នេសាទសំរាប់តែហូបដើម្បីចិញ្ចឹមជីវិត និង កសិករដែលពឹងផ្អែកយ៉ាងខ្លាំង (តែមិនទាំងស្រុងទេ) ទៅលើធនធានវារិជាតសំរាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។




រូបភាពទី ៣: ភាគរយនៃការបែងចែកចំនួនគ្រួសារនិងការប៉ាន់ស្មានប្រាក់ចំណូលសរុបប្រចាំឆ្នាំតាមកំរិតប្រាក់ចំណូល ( ប៉ាន់ស្មានសំរាប់ប្រាំខេត្ត)

រីឯអ្នកដែលមានប្រាក់ចំណូលខ្ពស់ គឺសំដៅទៅលើអ្នកនេសាទសិប្បកម្ម និង អាជីវករឡូត៍នេសាទ។ ភាពខុសគ្នានៃប្រាក់ចំណូលរវាងគ្រួសារតំរូវគឺជាបញ្ហាមួយដ៏សំខាន់ និងចំពោះមុខដែលចាំបាច់ត្រូវតែធ្វើ ការដោះស្រាយ។

*ការប៉ាន់ស្មានប្រាក់ចំណូលប្រចាំឆ្នាំសរុបសំរាប់គ្រួសារទាំងអស់ដែលរស់នៅដោយពឹងផ្អែកទៅលើធនធានជលផល នៅក្នុងខេត្តទាំងប្រាំ គឺមានប្រហែលជា ២៣៣លានដុល្លារអាមេរិក ដែលបង្ហាញឱ្យឃើញថាប្រាក់ចំណូលប្រចាំឆ្នាំក្នុងមួយនាក់ គឺ មានប្រហែលជា ១៧២ដុល្លារអាមេរិក ។ ទោះជាយ៉ាងណាក៏ដោយ ជាង៧០ភាគរយនៃគ្រួសារ ទាំងនោះរកបានប្រាក់ចំណូលតិចតួច ប្រហែលជា ៧៨ ដុល្លារអាមេរិកក្នុងមួយនាក់ៗ។ ភាគច្រើនពួកគេទាំងនោះ គឺជាអ្នកនេសាទគ្រួសារឬសំរាប់បរិភោគ និងអ្នកស្រែដែលពឹងផ្អែកយ៉ាងខ្លាំង (តែមិនទាំងស្រុង) ទៅលើប្រភពវារិជាតសំរាប់ការចិញ្ចឹមជីវិត។*

បន្ថែមទៅលើតំលៃដែលបានប៉ាន់ស្មានពីចំណូលរបស់គ្រួសារដែលបាយការណ៍ (ពីផលិតកម្មនិងការលក់) តំលៃនៃផលនេសាទសំរាប់ការប្រើប្រាស់នៅក្នុងផ្ទះត្រូវបានបន្ថែម។ ផ្អែកទៅលើការប្រើប្រាស់នៃផលនេសាទក្នុងតារាងទី២ និង តំលៃត្រីជាមធ្យមគឺ ០.២៥ ដុល្លារអាមេរិកក្នុងមួយគីឡូក្រាម ប្រហែលជា ៦២ ដុល្លារអាមេរិក ត្រូវបានប៉ាន់ស្មានជាតំលៃប្រើប្រាស់ជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារ។ តំលៃប្រើប្រាស់សរុបសំរាប់គ្រួសារទាំងអស់នោះមានប្រហែលជា ១៣ លានដុល្លារអាមេរិក ។ បន្ថែមលើសមាមាត្រនេះទៅលើចំណូលសរុបរបស់គ្រួសារទាំងនេះ បណ្តាលអោយមានការប៉ាន់ស្មានមួយដែលមានតំលៃប្រហែលជា ២២៨ លានដុល្លារអាមេរិក នៃតំលៃប្រើប្រាស់សំរាប់បរិភោគដោយផ្ទាល់នៃធនធានជលផល និងធនធានវារិជាតនៃតំបន់បឹងទន្លេសាប ។

ចំពោះសហគមន៍នៃតំបន់បឹងទន្លេសាបដែលយុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិតបង្ហាញថាចន្លោះផ្សេងគ្នានៃសកម្មភាពរកប្រាក់ចំណូល និង ជីវិតរស់នៅហើយនឹងផលប្រយោជន៍ដែលបានមកពីការប្រើប្រាស់ធនធានធម្មជាតិជាសាធារណៈត្រូវបានបូកបន្ថែមទៅលើចំនួនសរុបខាងលើ។ ផ្អែកទៅលើ Rab et al (2005) ប្រាក់ចំណូលជាមធ្យមប្រហែលជា ២៦ ដុល្លារអាមេរិកក្នុងមួយគ្រួសារ (ចំណូលខ្ពស់ជាងគេគឺនៅក្នុង

តារាងទី៨: តំលៃប្រើប្រាស់នៃផលផល

ក) ការប្រើប្រាស់ផលនេសាទជាមធ្យមសរុបប្រចាំឆ្នាំតាមគ្រួសារ *

| ខេត្ត | ការប្រើប្រាស់ក្នុងផ្ទះជាមធ្យម (គីឡូក្រាម) | | | |
|---|---|---|---|---|
| | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ | សរុប |
| កំពង់ឆ្នាំង | 136 | 172 | 150 | 153 |
| សៀមរាប | 723 | 240 | 128 | 364 |
| ជាមធ្យម | | | | 258 |

(*ទិន្នន័យពីតារាងទី២)

ខ) តំលៃសរុបមធ្យមក្នុងមួយគ្រួសារ (ថ្លៃឯកតាមធ្យម គឺប្រហែល ០.២៥ ដុល្លារក្នុងមួយគីឡូក្រាម)

| ខេត្ត | តំលៃនៃការប្រើប្រាស់ (ដុល្លារអាមេរិក) | | | |
|---|---|---|---|---|
| | នេសាទ | នេសាទផងនិងធ្វើស្រែផង | ធ្វើស្រែ | សរុប |
| កំពង់ឆ្នាំង | 33 | 42 | 37 | 37 |
| សៀមរាប | 177 | 59 | 31 | 89 |
| ជាមធ្យម | | | | 63 |

គ) តំលៃប្រើប្រាស់សរុបពីផលនេសាទរបស់គ្រួសារដែលពឹងផ្អែកលើវារិជាត

| ខេត្ត | តំលៃនៃការប្រើប្រាស់ (លានដុល្លារអាមេរិក) |
|---|---|
| កំពង់ឆ្នាំង | 1.8 |
| សៀមរាប | 3.6 |
| បាត់ដំបង | 2.8 |
| ពោធិ៍សាត់ | 2.4 |
| កំពង់ធំ | 2.4 |
| សរុប | 13.0 |

ប្រភព: ដោយផ្អែកទៅលើការអង្កេតរបស់ Rab *et al.* (2005)

ភូមិនេសាទ ៤២ ដុល្លារ អាមេរិក និងចំណូលទាបបំផុត នៅក្នុងភូមិអ្នកធ្វើស្រែប្រហែលជា១៦ដុល្លារអាមេរិក) ទទួលបានមកពីការប្រមូលនៃរុក្ខជាតិនៅក្នុងទឹក និង វារីសត្វ។ ខណៈពេលនោះតំលៃនេះជាតំលៃដែលទាប វាមានសារៈសំខាន់សំរាប់ ប្រជាជនដែលមានកំរិតចំណូលទាប ក្នុងនោះមានចូលរួមប្រហែលជា ២ ទៅ ៦ ភាគរយនៃប្រាក់ចំណូលដែលបានមកពីសកម្មភាពសេដ្ឋកិច្ចចំបងៗ។ តំលៃប៉ាន់ស្មាននៃធនធានធម្មជាតិជាសាធារណៈសំរាប់គ្រួសារដែលពឹងផ្អែកទៅ លើធនធានវារិជាត មានប្រាក់ចំណូលតិចជាង ២.០០០ដុល្លារអាមេរិក នៅក្នុងខេត្តទាំងប្រាំ គឺមានប្រហែលជា ៥លានដុល្លារអាមេរិក ដែលផ្តល់នូវតំលៃប៉ាន់ស្មាននៃប្រើប្រាស់ដោយផ្ទាល់សរុបមួយប្រើប្រាស់សំរាប់បរិភោគ ដោយផ្ទាល់នៃធនធានវារិជាតនៃបឹងទន្លេសាបគឺប្រហែលជា ២៣៣ លានដុល្លារអារិក ។

ការប៉ាន់ស្មានចំណូលគ្រួសារប្រចាំឆ្នាំជាមធ្យម ទៅតាមកំរិតចំណូល ដូចដែលបានធ្វើនៅទីនេះនាំអោយមានភាពខុសគ្នារវាងការពឹងផ្អែកនៃការចិញ្ចឹមជីវិតនៃសមគមន៍ដែលនៅជុំវិញបឹងទន្លេសាប។ ជាទូទៅគេអាចនិយាយបានថាភាគច្រើននៃប្រជាជនដែលរស់នៅជុំវិញបឹងទន្លេសាប ពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានវារិជាត។ កំរិតចំណូលទាបរបស់ពួកគេធ្វើអោយមានភាពងាយរងគ្រោះជាងអ្នកដែលមានកំរិតចំណូលខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់គួរអោយគូសបញ្ជាក់ថា ការប៉ាន់ស្មានដែលត្រូវបានរាយការណ៍នៅទីនេះ គឺ ផ្អែកទៅលើការសន្មតមួយចំនួន និង

ដោយមិនរាប់បញ្ចូលតំលៃប្រើប្រាស់ជាប្រយោលនិងតំលៃផ្សេងៗទៀតរបស់បឹងទន្លេសាបទេ។ ប្រសើរជាងនេះទៅទៀតនេះគឺជាតំលៃ "អប្បបរមា" មួយហើយប្រើប្រាស់តែដើម្បីបង្ហាញពីសារៈសំខាន់នៃធនធានជលផលនិងវារិជាតចំពោះប្រជាជនរស់នៅជុំវិញបឹងទន្លេសាបតែប៉ុណ្ណោះ។ លក្ខខណ្ឌកំណត់មួយផ្សេងទៀតគឺការប្រើប្រាស់ទិន្នន័យដែលបានមកពីការធ្វើការអង្កេតគ្រួសារនៅក្នុងខេត្តកំពង់ឆ្នាំង និង សៀមរាបដើម្បីផ្តល់នូវការប៉ាន់ស្មានសំរាប់បីខេត្តផ្សេងទៀត។ ការសិក្សាលំអិតជាងនេះទៅទៀតគឺជាតំរូវការមួយចាំបាច់ដើម្បីពង្រឹងនូវការប៉ាន់ស្មានទាំងនោះ។ គួរកត់សំគាល់ថានេះអាចជាលំហាត់ងាយស្រួលមួយ ឧទាហរណ៍ដូចជាការធ្វើអង្កេតនៅមូលដ្ឋាននៃគ្រួសារ ដែលរស់នៅក្នុងខេត្តបីផ្សេងទៀត ជាសំខាន់ដើម្បីទទួលបាននូវសមាមាត្រនៃគ្រួសារទាំងនោះនៅក្នុងប្រភេទភូមិខុសៗគ្នា។

*ការប៉ាន់ស្មានដែលត្រូវបានរាយការណ៍នៅទីនេះគឺតំលៃអប្បបរមា ដែលប្រើប្រាស់បឹងទន្លេសាបដោយផ្ទាល់។ តំលៃនៃអេកូឡូស៊ី សង្គម និង សេដ្ឋកិច្ចផ្សេងទៀតនៃបឹងទន្លេសាប និងប្រព័ន្ធអេកូឡូស៊ីនៃតំបន់ដីសើមទូទៅ ចាំបាច់ត្រូវតែគិតគូរ និងពិភាក្សានៅក្នុងការរៀបចំគោលនយោបាយនៃការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃធនធានទាំងនេះចំពោះការចិញ្ចឹមជីវិតរបស់ប្រជាជន ។*

វាមានសារៈសំខាន់យ៉ាងខ្លាំងដើម្បបញ្ជាក់ថាការគិតគូរវែងឆ្ងាយគឺសង្កត់ធ្ងន់ទៅលើការទាញយកជាចំបងនៃតំលៃសេដ្ឋកិច្ចរបស់ធនធានជលផលនិងវារិជាតមួយចំណែករបស់បឹងទន្លេសាប។ តំលៃនៃសង្គម និង ប្រពន្ធ័អេកូឡូស៊ីនៃធនធានទាំងនោះមិនទាន់ត្រូវបានគេគិតគូរនៅឡើយ។ សំខាន់ជាងនេះទៅទៀតធនធានជលផល និង វារិជាតគឺជាផ្នែកមួយនៃប្រពន្ធ័អេកូឡូស៊ីនៃតំបន់ដីសើមទូទៅមួយរបស់បឹងទន្លេសាបដែលរួមមាន ទន្លេ ព្រែក បឹង វាលស្រែ តំបន់ព្រៃលិចទឹក និង តំបន់ផ្សេងៗទៀតដែលលិចទឹកជាអចិន្រ្តៃយ៍និងតាមរដូវកាល។ ដូច្នេះ តំលៃនៃ សេដ្ឋកិច្ច សង្គម និង អេកូឡូស៊ីគឺមានតម្លៃធំធេងណាស់ហើយចាំបាច់ត្រូវតែបញ្ចូលទៅក្នុងការពិភាក្សា ជាពិសេសគឺការគិតគូរអំពីការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនិងភាពពឹងផ្អែកទៅលើធនធានរបស់ពួកគេ ដើម្បីរៀបចំគោលនយោបាយប្រើប្រាស់ធនធាន និង ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត (Bonheur *et al.*, 2005)។

## ៥. បញ្ហានិងផលវិបាកក្នុងការទ្រទ្រង់ដល់ការធ្វើនេសាទដើម្បីចិញ្ចឹមជីវិត

សហគមន៍ដែលពឹងផ្អែកទៅលើធនធាននៅក្នុងទឹកនៅជុំវិញបឹងទន្លេសាប បានជួបប្រទះនិងផលវិបាកចំពោះមុខមួយចំនួននៅក្នុងការទ្រទ្រង់ដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។ បើគិតពីទស្សនៈវិស័យនៃបរិស្ថាន និងអេកូឡូស៊ី ពួកគេងាយនឹងទទួលរងគ្រោះនូវឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុក្នុងរយៈពេលវែង និង ខ្លី ជាឧទាហរណ៍ ការប្រែប្រួលនៃចំនួនទឹកភ្លៀងកើតនិងរយៈពេលទឹកជំនន់ និង ទំហំនៃតំបន់លិចទឹក។ ការប្រែប្រួលទាំងនេះអាចបណ្តាលមកពីសកម្មភាពមនុស្សដូចជា ការសាងសង់ទំនប់ទឹក ការកាប់បំផ្លាញព្រៃឈើ ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតនៅក្នុងកសិកម្ម និង ការអភិវឌ្ឍន៍ដីធ្លី។ លទ្ធផលជាក់ស្តែងផ្ទាល់មួយនៃការប្រែប្រួលអំពីកត្តាមនុស្សនិងលក្ខខណ្ឌធម្មជាតិទៅលើធនធានជលផលនិងវារិជាត គឺការបាត់បង់នូវកន្លែងត្រីពង និងជំរកត្រី ដែលបណ្តាលអោយមានការថយចុះនៃផលនេសាទ។ ដូច្នេះសកម្មភាពផ្សេងៗទៀតដែលមានផលប៉ះពាល់មិនល្អទៅលើផលនេសាទ និង ចំណូលរបស់សហគមន៍ គឺការប្រើប្រាស់ឧបករណ៍នេសាទបំផ្លិចបំផ្លាញនិងខុសច្បាប់ និង ការនេសាទហួសកំរិត។ ការអភិវឌ្ឍន៍ផ្សេងៗ រួមបញ្ចូលទាំងវារីវប្បកម្ម កសិកម្ម ទេសចរណ៍ និង ការសាងសង់ផ្ទះអាចប៉ះពាល់ផងដែរនូវការបំផ្លិចបំផ្លាញស្ថានភាពនៃប្រពន្ធ័វារីអេកូឡូស៊ីនៃបឹងទន្លេសាប។

ទាក់ទងទៅនឹងបញ្ហាខាងលើនេះ សហគមន៍នៅ

ក្នុងបឹងទន្លេសាបត្រូវជួបប្រទះជាមួយបញ្ហាចំពោះមុខនៃសេដ្ឋកិច្ច និង សង្គម។ ដូចគ្នានឹងលទ្ធផលទូទៅដែលបានរកឃើញនៅជុំវិញពិភពលោកដែរ ដូចជាកំណើនប្រជាជន ផលវិបាកនៃសង្គម និង ផ្នែកសេដ្ឋកិច្ចដែលបណ្ដាលមកពីការថយចុះនៃធនធាន ការកើនឡើងនៃសំពាធទៅលើការនេសាទ ការប្រែប្រួលនៃភាពជាម្ចាស់កម្មសិទ្ធ និងលទ្ធភាព (ចំពោះធនធាននិងទីផ្សារ) និងភាពមិនស្មើគ្នានៃយេនឌ័រនិងជនជាតិ គឺជាបញ្ហាចំបងដែលបានជួបប្រទះនៅក្នុងការទ្រទ្រង់នៃការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលរស់នៅក្នុង និងជុំវិញបឹងទន្លេសាប។ ទំនាស់រវាងក្រុមអ្នកប្រើប្រាស់ធនធានត្រូវបានធ្វើអោយមានភាពកាន់តែធ្ងន់ធ្ងរឡើងដោយអ្នកនេសាទតាមរដូវកាល ដែលដណ្ដើមកាន់កាប់មានមុខរបរមួយផ្នែកនៃបឹងទន្លេសាបនៅក្នុងរដូវធ្វើនេសាទ និង អ្នកដែលតែងតែប្រើប្រាស់នូវឧបករណ៍ ខុសច្បាប់ (MAFF-CNMC, 2003)។ ជាចុងក្រោយ ប្រជាជនដែលមាន មុខរបរចិញ្ចឹមជីវិត ដោយពឹងផ្អែកទៅលើការប្រើប្រាស់ធនធានជលផលវារិជាត និង ធនធានធម្មជាតិជាសាធារណៈជាយូរណាស់មកហើយ មិនមានជំរើសមុខរបរផ្សេងក្រៅពីរបរនេះទៀតឡើយ។

មានផលវិបាកជាច្រើន ដូចជា កំរិតអប់រំទាប និងមធ្យោបាយធ្វើដំណើរ ដែលធ្វើអោយមានឧបសគ្គបន្ថែមដល់ឱកាសនៃសកម្មភាពរកប្រាក់ចំណូលផ្សេងៗទៀត (Israel *et al.*, 2005)។

ផលវិបាកភាគច្រើនផ្សេងទៀតចំពោះការទ្រទ្រង់មុខរបរនេសាទដើម្បីចិញ្ចឹមជីវិត គឺអភិបាលកិច្ច និង កិច្ចព្រមព្រៀងរវាងស្ថាប័ននានា ដែលចាំបាច់សំរាប់ការអនុវត្តន៍កំណែទំរង់គោលនយោបាយជលផលនាពេលបច្ចុប្បន្ននេះ។ ចាប់តាំងពីការចាប់ផ្ដើមធ្វើការកែទំរង់នេះនៅក្នុងខែតុលា ឆ្នាំ២០០០ មកមានសហគមន៍នេសាទប្រហែលជា ៤៤០ ត្រូវបានបង្កើតឡើងតាមរយៈគំនិតផ្ដួចផ្ដើមនៃនាយកដ្ឋានជលផល (DOF) និងការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលនានា ដែលទាក់ទងទៅនឹងផ្នែកជលផល និង បរិស្ថានផ្សេងៗទៀត។ ផលប៉ះពាល់ នៃកំណែទំរង់នេះទៅលើការកាត់បន្ថយភាពក្រីក្រ និង សុវត្ថិភាពស្បៀង គឺជាផ្នែកមួយនៃគោលដៅចំបង ដែលត្រូវបានលើកយកមកពិភាក្សា និងជាដំណាក់កាលដំបូងនិង "ជាផ្លូវការ" នៃការវាយតំលៃមួយដែលត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៣/២០០៤ ក្នុងខេត្តទាំងបី (កំពង់ចាម ពោធិសាត់ និងតាកែវ) ដោយការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និង ស្ថាប័នផ្សេងៗទៀត (សូមមើលលំអិតនៅក្នុង CFDO និង DFID, 2004)។ ជាទូទៅការវាយតំលៃបង្ហាញអោយឃើញពីភាពប្រែប្រួលជាវិជ្ជមានជាច្រើននៅក្នុងការកាត់បន្ថយភាពក្រីក្រ ចំពោះប្រជាជនក្រីក្រភាគច្រើន ជាពិសេសចំពោះអ្នកនេសាទគ្រួសារ កសិករ និង អ្នកទិញលក់ត្រី ដែលជួយបង្កើននូវប្រាក់ចំណូលនិងឱកាសការងារផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ ការពង្រឹងដំបូងនៃសុវត្ថិភាពស្បៀងអាចមិនត្រូវបានទ្រទ្រង់ដោយសារមានការប្រកួតប្រជែងខ្លាំង និង ការថយចុះនៃមូលដ្ឋានធនធាន។ ជំរើសនៃការប្រកបរបរចិញ្ចឹមជីវិតចាំបាច់ត្រូវតែស្វែងរកបន្ថែមទៀត ដើម្បីកាត់បន្ថយនូវសំពាធទៅលើការប្រើ ប្រាស់ធនធានជលផល និង វារិជាត។ ការិយាល័យអភិវឌ្ឍន៍សហគមន៍ (CFDO) និង DFID (2004) បានផ្ដល់ជាអនុសាសន៍ស្ដីអំពីការកសាងសមត្ថភាពនិងការពង្រឹងសហគមន៍ និង ស្ថាប័នផ្សេងៗដើម្បីគ្រប់គ្រងជលផល និង ជួយសំរួលនូវដំណើរការអនុវត្តន៍។ ចំនុចនេះអាចត្រូវបានបញ្ជាក់នៅក្នុងការសិក្សាផ្សេងៗទៀត (ឧទាហរណ៍ Keskinen, 2003; Israel *et al.*, 2005) ដោយហេតុថាកំណែទំរង់នេះបានកើតឡើងឆាប់រហ័សពេក ដែលធ្វើឱ្យសហគមន៍ និង ស្ថាប័នមួយចំនួន មិនទាន់ត្រៀមខ្លួនរួចជាស្រេចចំពោះការប្រែប្រួលទាំងអស់ និង ក្របខណ្ឌច្បាប់ដែលត្រូវការសំរាប់ការអនុវត្ត និង ត្រួតពិនិត្យ នៅមិនទាន់បានបង្កើតនៅឡើយ។

ផលវិបាកទាំងបីប្រភេទដែលបានបង្ហាញខាងលើមានដូចជា បរិស្ថាននិងប្រពន្ធ័អេកូឡូស៊ី សេដ្ឋកិច្ចនិងសង្គម និង គោលនយោបាយនិងការគ្រប់គ្រង គួរតែធ្វើការពិភាក្សាបន្ថែមទៀត។ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៤

មានអ្នកចូលរួមចំនួន៤០នាក់ដែលមកពីវិស័យជលផលសំខាន់ៗក្នុងជួររាជរដ្ឋាភិបាល ដូចជា នាយដ្ឋានជលផល ការិយាល័យជលផលខេត្ត និង ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានមកចូលរួមប្រជុំដើម្បីគិតគូរនិងពិចារណាថាតើការឆ្លើយតបអ្វីខ្លះដែលចាំបាច់សំរាប់ដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ។ សេចក្តីសង្ខេបនៃអនុសាសន៍របស់ពួកគេត្រូវបានបង្ហាញនៅក្នុងតារាងទី៩។ តាមទស្សនៈវិស័យនៃបរិស្ថាននិងប្រពន្ធ័អេកូឡូស៊ី គន្លឹះបញ្ហាមួយចំនួនត្រូវបានកំនត់ដោយអ្នកចូលរួមក្នុងសិក្ខាសាលាគឺជាបញ្ហាដែលទាក់ទងទៅនឹងការបាត់បង់ព្រៃលិចទឹក និង ជំរកត្រីពង ផលប៉ះពាល់នៃការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និង ការអភិវឌ្ឍន៍ផ្សេងៗទៀត។

មានការចាំបាច់សំរាប់ធ្វើការសិក្សាស្រាវជ្រាវដើម្បីវាយតំលៃលើភាពប៉ះពាល់ចំពោះសកម្មភាពនានា រួមមានការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ចំពោះធនធានជលផល និង ប្រពន្ធ័វារីអេកូឡូស៊ី។ ពិសេសការចាប់អារម្មណ៍ទៅលើការគិតគូរអំពីជំរកត្រីពងសំខាន់ៗ និងការស្នើរអោយបង្កើតកន្លែងបំរុងទុកដែលគ្មានការនេសាទនៅថ្នាក់សហគមន៍ (មានន័យថាមានការចូលរួមពីសហគមន៍)។ គំនិតផ្តួចផ្តើមនេះ អាចមានអត្ថប្រយោជន៍ផងដែរក្នុងការពារការនេសាទខុសច្បាប់ និងការដោះស្រាយបញ្ហាអនុវត្តន៍ច្បាប់នៅក្នុងកន្លែងបំរុងទុកដែលមានស្រាប់ (MAFF-CNMC, 2003; Baran *et al.*, in press)។

តារាងទី៩: សង្ខេបនៃចំលើយដែលត្រូវការដើម្បីដោះស្រាយបញ្ហាក្នុងការធ្វើអោយមាននិរន្តភាពនៃរបរចិញ្ចឹមជីវិតរបស់ប្រជាជនដែលរស់នៅក្នុង និងជុំវិញបឹងទន្លេសាប

| **កត្តា/គន្លឹះបញ្ហា** | **ការស្រាវជ្រាវ/សកម្មភាពចាំបាច់** |
|---|---|
| **១.និរន្តភាពនៃបរិស្ថាន** | |
| កង្វះខាតព័ត៌មានអំពីជំរកត្រីសំខាន់ៗ និងមុខងារកន្លែងបំរុងទុក | ចាំបាច់ត្រូវតែធ្វើការស្រាវជ្រាវស្តីអំពីជំរកត្រីសំខាន់ៗ ដើម្បីផ្តល់នូវការការពារសមស្រប និង ដើម្បីបង្កើត តំបន់អភិរក្សនៅថ្នាក់មូលដ្ឋាន អាចជាតំបន់ដែលគ្មាន ការនេសាទ។ |
| ការប្រើប្រាស់ ឧបករណ៍នេសាទដែលធ្វើអោយវិនាស និងធ្វើអោយអន្តរាយ | ចាំបាច់ត្រូវតែកំណត់នូវប្រភេទឧបករណ៍នេសាទ ដែលធ្វើអោយបំផ្លិចបំផ្លាញ ជាពិសេសឧបករណ៍ដែលមិនអនុញ្ញាតអោយប្រើប្រាស់ពីពេលមុន ព្រមទាំងកំណត់នូវផលប៉ះពាល់ដល់ចំនួនត្រីសរុប។ |
| ផលប៉ះពាល់នៃទំនប់ទឹកប៉ែកខាងលើទៅលើ បឹងទន្លេសាប | ចាំបាច់ត្រូវតែកំណត់នូវវិសាលភាពនៃភាពប្រែប្រួលរបស់របបទឹកនៃទន្លេមេគង្គ និងផលប៉ះពាល់ ទៅលើផ្នែកជលផល។ |
| ការថយចុះនៃព្រៃលិចទឹក | ចាំបាច់ត្រូវតែធ្វើការស្រាវជ្រាវស្តីពីប្រព័ន្ធអេកូឡូស៊ី ដើម្បីវាយតំលៃផលប៉ះពាល់នៃភាពថយ ចុះរបស់ព្រៃលិចទឹកក្នុងវិស័យជលផល។ |
| ទំនាស់រវាងការប្រើប្រាស់នៃប្រព័ន្ធស្រោចស្រព កសិកម្ម, នេសាទ, វារីវប្បកម្ម និង ការប្រើប្រាស់ ដីទៃទៀត | ចាំបាច់ត្រូវតែធ្វើការវាយតំលៃផលប៉ះពាល់នៃភាព ខុសគ្នារវាងការប្រើប្រាស់នៃប្រព័ន្ធវារីអេកូឡូស៊ីនៅ បឹងទន្លេសាប ព្រមទាំងភាពសំរេចទៅបាន និងតួនាទីក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព។ |

| | |
|---|---|
| **២.ចិរភាពនៃសេដ្ឋកិច្ចសង្គម** | |
| វិធីសាស្ត្រដែលមិនមានប្រសិទ្ធភាពនៃការប្រមូល និងការវិភាគទិន្នន័យ | ចាំបាច់ត្រូវតែលើកកំពស់នូវការប្រើប្រាស់ដែលមានភាពប្រហាក់ប្រហែលគ្នានូវវិធីសាស្ត្រប្រមូលទិន្នន័យ និងការវិភាគ ដើម្បីសង្កេតពីភាពប្រែប្រួល និង និន្នាការណ៍របស់វា ។ |
| ទំនាស់ដែលបណ្តាលមកពីជនជាតិផ្សេងៗគ្នា ដែលរស់នៅក្នុងសហគមន៍បឹងទន្លេសាប (ដូចជា ខ្មែរ វៀតណាម និង ចាម) | ចាំបាច់ត្រូវតែប្រមូលព័ត៌មានជាមូលដ្ឋានដើម្បី បែងចែកភាពខុសប្លែកគ្នា ឧ.ដូចជាចំនួនអ្នកនេសាទ មធ្យោបាយនៃការប្រកបរបរចិញ្ចឹមជីវិត មធ្យោបាយ ដោះស្រាយទំនាស់សំរាប់ក្រុមជនជាតិ នីមួយៗ។ |
| ទំនាស់រវាងអ្នកនេសាទចំណូលក្រៅតាមរដូវកាល និងសហគមន៍ក្នុងមូលដ្ឋាន | ចាំបាច់ត្រូវតែស្វែងយល់ពីវិធីសាស្ត្រការលើកទឹកចិត្តនិងបែបផែននៃអ្នកចំណូលស្រុក ផលប៉ះពាល់នៃការប្រើប្រាស់ធនធាន ព្រមទាំងកំណត់ (និងទទួលបាននូវភាពព្រមព្រៀងស្តីពី) សិទ្ធិប្រើប្រាស់មួយសមស្រប។ |
| ច្រកចូលមានកំណត់ទៅក្នុងទីផ្សារ នៅក្នុងថ្នាក់ ឃុំ និង ឥណទានខ្នាតតូច (បណ្តាលអោយមានការជំពាក់បំណុលច្រើនដល់ពួកឈ្មួញកណ្តាល) | ចាំបាច់ត្រូវតែស្វែងយល់អំពីលទ្ធិភាពទីផ្សារ និង ប្រព័ន្ធទីផ្សារ ប្រភពឥណទាន និងប្រាក់ចំណូលពិតរបស់អ្នកនេសាទជាលក្ខណៈគ្រួសារ។ |
| កង្វះខាតនៃជំនាញបច្ចេកទេស និងមូលធនសំរាប់លើកកំពស់វិស័យចង្វាក់ផលិតផលជលផល | ចាំបាច់ត្រូវតែអភិវឌ្ឍនូវវិធីសាស្ត្រ និងបច្ចេកទេសថ្មី ដើម្បីបង្កើននូវវិស័យខ្សែចង្វាក់ផលិតផលជលផល ដោយរួមបញ្ចូលទាំងតំលៃបន្ថែម។ |
| កង្វះខាតនៃជំរើសមុខរបរចិញ្ចឹមជីវិតផ្សេងទៀត | ចាំបាច់ត្រូវតែស្វែងរកពីជំរើសនៃរបរចិញ្ចឹមជីវិត ដែលឆ្លើយតបទៅនឹងតំរូវការ និង គោលបំណងរបស់ សហគមន៍។ |
| ភាពខ្វះខាត វីតាមីនក្នុងសហគមន៍នេសាទ | ចាំបាច់ត្រូវតែកំណត់នូវវិធីដើម្បីពង្រឹងនូវការចូល រួមនៃត្រីក្នុងរបបអាហារ។ |
| កង្វះខាតក្នុងការយល់ដឹងនូវការប្រែប្រួលតួនាទី របស់ស្ត្រីនៅក្នុងបរិបថសហគមន៍នេសាទ | ចាំបាច់ត្រូវតែពិនិត្យលើភាពប្រែប្រួល ក្នុងការប្រើប្រាស់ធនធានសំរាប់ស្ត្រី និងការចូលរួមរបស់ពួកគេក្នុងការធ្វើនេសាទ ហើយធ្វើការអង្កេត ថាតើពួកគេត្រូវការជំនាញថ្មីដែរឬទេ និងគាំទ្រការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពនៃការធ្វើសេចក្តីសំរេច និងសេដ្ឋកិច្ច។ |
| **៣.គោលនយោបាយ និងការគ្រប់គ្រង** | |
| ផលប៉ះពាល់នៃច្បាប់ និងគោលនយោបាយទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជន នៅក្នុងវិស័យជលផល និងវិស័យផ្សេងៗទៀត | ចាំបាច់ត្រូវតែធ្វើការស្រាវជ្រាវអំពីផលប៉ះពាល់នៃច្បាប់ធនធានធម្មជាតិមួយទៅលើច្បាប់ផ្សេងៗទៀត និងត្រួតពិនិត្យទៅភាពត្រូវគ្នារបស់វា។ |

តារាងទី៥ (ត)

| | |
|---|---|
| កង្វះខាតនៃការយល់ដឹងពីច្បាប់ វិធាន និងបទបញ្ជាផ្សេងៗ ជាពិសេសទៅលើអ្នកចំណូលស្រុកថ្មី | ចាំបាច់ត្រូវតែពិចារណាទៅលើនិយមន័យថ្មីមួយដើម្បី ការធ្វើនេសាទប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលដែលបណ្តាលមកពីសំពាធនៃ កំនើនការនេសាទ និងពង្រឹងនូវការយល់ដឹង |
| កង្វះខាតនៃគ្រឿងលើកទឹកចិត្តដើម្បីចូលរួមក្នុងក្រុមគ្រប់គ្រងធនធានធម្មជាតិ | ចាំបាច់ត្រូវតែលើកកំពស់ការយល់ដឹងជាពិសេស ក្នុងចំណោមអ្នកចំនូលស្រុកតាមរដូវកាល ដែលគ្មានភាពជិតស្និត និងផ្សារភ្ជាប់ជាមួយធនធានធម្មជាតិ |
| ប្រសិទ្ធភាពនៃសហគមន៍នេសាទ | ចាំបាច់ត្រូវតែវាយតំលៃថាតើវិមជ្ឈការ កំពុងតែដំណើរការដែរឬទេ ឧទាហរណ៍ទាក់ទងទៅនឹងការចែកចាយផលប្រយោជន៍ រាប់បញ្ចូលឬមិនបញ្ចូលបញ្ហាផ្សេងៗ ដែលផ្អែកទៅលើទំនៀមទំលាប់ អនុវត្តន៍ដែល មានស្រាប់នៅទីនោះ |
| ផលប៉ះពាល់ពី អង្គការពាណិជ្ជកម្មពិភពលោក WTO | ចាំបាច់ត្រូវតែពិនិត្យពីផលប៉ះពាល់នៃអង្គការពាណិជ្ជកម្មពិភពលោកទៅលើជលផលនេសាទទឹកសាប និង អ្នកនេសាទជាលក្ខណៈគ្រួសារនៅតំបន់បឹងទន្លេសាប ឧ.ថាតើវានឹងលើកកំពស់ដល់ផ្នែកពាណិជ្ជកម្ម ផ្លាស់ប្តូរលក្ខណៈនៃជំនួញនិងបង្កើននូវតំរូវការ។ |

គន្លឹះបញ្ហា ដែលទាក់ទងទៅនិងសេដ្ឋកិច្ចសង្គម និងការចិញ្ចឹមជីវិតរបស់សហគមន៍នៅក្នុងបឹង ទន្លេសាប រួមមាន ទំនាស់រវាងអ្នកពាក់ពន្ធ័ (ជាពិសេសអ្នកនេសាទតាមរដូវ និង អ្នកចំណូលថ្មីដែលប្រើប្រាស់នូវឧបករណ៍នេសាទខុសច្បាប់) លទ្ធភាពរកទីផ្សារនិងឥណទាននៅមានកំណត់ និងកង្វះខាតនៃជំរើសរបរចិញ្ចឹមជីវិត។ យោបល់សំខាន់នានាដែលត្រូវបានផ្តល់ជាអនុសាសន៍ដើម្បីដោះស្រាយនូវកង្វល់ទាំងអស់នេះ រួមមានការស្រាវជ្រាវដែលងាយយល់នឹងជាប្រពន្ធ័ និងការប្រមូលទិន្នន័យដែលទាក់ទងនឹងពតិមានគ្រឹះនៃសេដ្ឋកិច្ចនិងសង្គម ដូចជា ការផ្លាស់ប្តូរបែបផែននៃការនេសាទ ផលនេសាទ សមាសភាគនៃផលនេសាទ ការងារចំណូលស្រុករបស់អ្នកនេសាទ ភាពខុសគ្នានៃជនជាតិ និង ចរឹតលក្ខណៈនៃការចិញ្ចឹមជីវិតផ្សេងៗទៀត។ ការស្រាវជ្រាវដើម្បីលើកកំពស់លទ្ធភាពក្នុង ទីផ្សារ វិភាគទានរបស់ត្រីនៅក្នុងអាហារូបត្ថម្ភរបស់មនុស្ស និងខ្សែសង្វាក់ផលិតផលជលផល គឺត្រូវបានលើកមកពិភាក្សាផងដែរ។ បន្ថែមលើនេះសំណើមួយត្រូវបានធ្វើឡើងដើម្បីពិនិត្យអំពីការប្រែប្រួលនៃតួនាទីរបស់ស្ត្រីថ្មីមួយនៅក្នុងបរិបទនៃសហគមន៍នេសាទ ឧទាហរណ៍កំនើននៃការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងការធ្វើសេចក្តីសំរេចចិត្ត។

ដូចដែលបានបញ្ជាក់ពីខាងលើ ការងារបន្ថែមទៀតគឺត្រូវការជាចាំបាច់ណាស់ដើម្បីបង្កើននូវការប៉ាន់ស្មានតំលៃនៃធនធានជលផលនិងវារិជាត តាមរយៈការបញ្ចូលតំលៃប្រើប្រាស់និងមិនប្រើប្រាស់ផ្សេងៗទៀត ព្រមទាំងការគិតគូរអំពីទំនាក់ទងរវាងការចិញ្ចឹមជីវិត និងប្រពន្ធ័អេកូឡូស៊ី។ ការសិក្សាជាច្រើនចាំបាច់ត្រូវតែធ្វើឡើងដើម្បី ទទួលបាននូវការយល់ដឹងអោយកាន់តែប្រសើរឡើងអំពីតំលៃ និងបកស្រាយអំពីភាពខុសគ្នា ដូចជា ភាពខុសគ្នានៃប្រាក់ចំណូលក្នុងគ្រួសាររបស់អ្នកនេសាទជាលក្ខណៈគ្រួសារ លក្ខណៈមធ្យមនិងអាជីវករឡូត៍នេសាទ និង ការប្រែប្រួលកំរិតនៃការពឹងផ្អែករបស់ការប្រកបរបរចិញ្ចឹមជីវិតទៅលើប្រពន្ធ័អេកូឡូស៊ីនៃបឹងទន្លេសាប។

នៅក្នុងគោលនយោបាយគ្រប់គ្រង តំរូវការដែល

ត្រូវបានលើកឡើង រួមមានការយល់ដឹងអំពីផលប៉ះពាល់នៃច្បាប់និងបទបញ្ញត្តិផ្សេងៗទៅលើការចិញ្ចឹមជីវិតរបស់ប្រជាជន ភាពស៊ីចង្វាក់គ្នានៃច្បាប់គ្រប់គ្រងធនធានធម្មជាតិផ្សេងៗ តំរូវការសំរាប់ការកំនត់និយមន័យថ្មី (ឧទាហរណ៍ នេសាទគ្រួសារ) ដើម្បីធ្វើអោយមានភាពស៊ីគ្នាជាមួយការប្រែប្រួលក្នុងបែបផែននៃការនេសាទនិងការប្រើប្រាស់ឧបករណ៍នេសាទ។ ប្រសិទ្ធភាពនៃកំណែទំរង់ គោលនយោបាយត្រូវតែធ្វើការវាយតំលៃមួយជាចាំបាច់ ជាពិសេសចំពោះការបែងចែកផលប្រយោជន៍និងបញ្ហានៅខាងក្នុង/ខាងក្រៅរបស់អ្នកពាក់ព័ន្ធ។ ជាចុងក្រោយមានភាពចាំបាច់មួយទៀតត្រូវតែពិនិត្យផងដែរ អំពីផលប៉ះពាល់នៃគោលនយោបាយរបស់អង្គការពាណិជ្ជកម្មពិភពលោកទៅលើការនេសាទទឹកសាបនិងចំពោះអ្នកនេសាទជាលក្ខណៈគ្រួសារនៅតំបន់បឹងទន្លេសាប ចំពោះការលើកកំពស់ដល់ផ្នែកពាណិជ្ជកម្ម ដែលនាំអោយមានការផ្លាស់ប្តូរលក្ខណៈនៃជំនួញនិងបង្កើននូវតំរូវការ។

## ៦. សន្និដ្ឋាន

ការនេសាទគឺជាសកម្មភាពសំខាន់មួយសំរាប់ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់បឹងទន្លេសាប ដែលតំណាងអោយមុខរបររបរចំបងរបស់ប្រជាជនជាងមួយភាគបីដែលរស់នៅតំបន់នោះ។ ទោះជាយ៉ាងណាក៏ដោយ សារៈសំខាន់នៃប្រព័ន្ធវារីអេកូឡូស៊ីនៃបឹងទន្លេសាប មានតំលៃលើសពីផលនេសាទដែលបានមកពីធនធានជលផលទៅទៀត ពីព្រោះថាប្រជាជនដែលរស់នៅក្នុងនិងជុំវិញបឹងទន្លេសាបបានប្រកបសកម្មភាពរកប្រាក់ចំណូល និងរបរចិញ្ចឹមជីវិតផ្សេងៗទៀតរួមមានការធ្វើស្រែចំការ ការប្រមូលអុស និងការប្រើប្រាស់ធនធានធម្មជាតិជាសាធារណៈ។ លើសពីនេះទៅទៀត ភាពមានមុខរបរជាច្រើនគឺជាចរិតលក្ខណៈសេដ្ឋកិច្ចសង្គមសំខាន់មួយរបស់សហគមន៍ នៅក្នុងបឹងទន្លេសាប ដោយនាំមកនូវការពិចារណាជាចំបងថា ការប្រកបរបរចិញ្ចឹមជីវិតចាំបាច់ត្រូវតែយកចិត្តទុកដាក់ទៅលើភាពពឹងផ្អែករបស់ប្រជាជនទៅលើប្រព័ន្ធវារីអេកូឡូស៊ីទាំងមូល។

តំលៃប៉ាន់ស្មានដែលបានមកពីតំលៃប្រើប្រាស់ដោយផ្ទាល់នៃធនធានជលផល និងវារិជាត បង្ហាញអំពីភាពខុសគ្នាយ៉ាងខ្លាំងរវាងគ្រួសារដែលមានកំរិតចំណូលផ្សេងៗគ្នា។ នៅពេលដែលប្រាក់ចំណូលសរុបប្រចាំឆ្នាំដែលបាន មកពីការប្រើប្រាស់ដោយផ្ទាល់របស់គ្រួសាររស់នៅពឹងផ្អែកទៅលើធនធានជលផលនៅក្នុងខេត្តទាំងប្រាំ គឺត្រូវបានប៉ាន់ស្មានថាប្រហែលជា ២៣៣ លានដុល្លារអាមេរិកនោះ គ្រួសារដែលមានចំណូលទាបជាង ១០០០ដុល្លារអាមេរិក មានតែមួយភាគបីប៉ុណ្ណោះ។ គ្រួសារដែលមានចំណូលទាបទាំងនេះ (រួមមានប្រហែលជា ៧០% នៃគ្រួសារទាំងអស់) រកប្រាក់ចំណូលក្នុងម្នាក់ៗបានត្រឹមតែ ៧៨ ដុល្លារអាមេរិកតែប៉ុណ្ណោះ។ ពួកគេភាគច្រើន គឺជាអ្នកនេសាទសំរាប់តែបរិភោគនៅក្នុងគ្រួសារ និងកសិករដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានវារិជាតសំរាប់ការប្រកបរបរ ចិញ្ចឹមជីវិតរបស់ពួកគេ។ តំលៃ និងសារៈសំខាន់នៃប្រព័ន្ធវារីអេកូឡូស៊ីរបស់បឹងទន្លេសាប មានសារៈសំខាន់ខ្លាំងណាស់ បើគិតអំពីកង្វះខាតជំរើសនៃការងារផ្សេងៗទៀតរបស់ប្រជាជនទាំងនោះ។

គេគិតថាយ៉ាងតិច ៥០% នៃផលនេសាទទឹកសាបសរុបបានមកពីការនេសាទជាលក្ខណៈគ្រួសារ និងការនេសាទនៅតាមវាលស្រែលិចទឹក (MAFF-CNMC, 2003) ហើយផ្អែកទៅលើសារៈសំខាន់នៃធនធានជលផលនិងវារិជាតសំរាប់ការចិញ្ចឹមជីវិតរបស់ប្រជាជនច្រើនជាងមួយលាននាក់ដែលរស់នៅក្នុង និង ជុំវិញបឹងទន្លេសាប ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ គេត្រូវតែគិតគូរយ៉ាងខ្លាំងនិងរកកិច្ច ប្រឹងប្រែងដោយផ្ទាល់នានា ដែលធ្វើឡើងជាចាំបាច់ដើម្បីធានាអោយមាននិរន្តរភាពនៃការប្រកបរបរ ចិញ្ចឹមជីវិតរបស់ពួកគេ។ កំណែទម្រង់នៃគោលនយោបាយនាពេលបច្ចុប្បន្ននេះ តាមរយៈការផ្តោតទៅលើការគ្រប់គ្រងសហគមន៍ដែលពឹងផ្អែកទៅលើធនធានធម្មជាតិ គឺជាដំណាក់កាលសំខាន់មួយដែលចាំបាច់ត្រូវតែគាំទ្រដោយកិច្ចព្រមព្រៀងរវាងស្ថាប័នដែលជាប់ពាក់ព័ន្ធនិងប្រព័ន្ធនៃ

អភិបាលកិច្ចមួយដែលសមស្រប។ ទាំងនេះអាចបណ្តាលអោយមានការផ្លាស់ប្តូរនៃចំនុចប្រសព្វរបស់ការស្រាវជ្រាវនិងគោលនយោបាយអំពី បញ្ហានៃការប្រកបរបរចិញ្ចឹមជីវិតនិងភាពក្រីក្រ និង អំពីទស្សនវិស័យនៃធនធាន (ឧទាហរណ៍ ការនេសាទហួសកំនត់) ទៅជាទស្សនវិស័យនៃអភិបាលកិច្ចនានា (ដូចជាការយល់ដឹងនូវយន្តការណ៍នៃស្ថាប័នសង្គមដែលដឹកនាំ និង គ្រប់គ្រងទៅលើសិទ្ធិរបស់ប្រជាជនក្នុងការប្រើប្រាស់ធនធានធម្មជាតិ (Béné, 2003))។ បែបផែននៃអន្តរអភិបាលកិច្ចមួយដែលពាក់ពន្ធ័ទៅនិងសកម្មភាពនិងការចូលរួមរបស់អ្នកពាក់ពន្ធ័ទាំងអស់ ដើម្បីដោះស្រាយបញ្ហាសង្គមនិងបង្កើតនូវឱកាសការងារនានា (Kooiman *et al.*,2003) គឺជាឧទាហរណ៍នៃប្រពន្ធ័មួយដែលអាចប្រកបទៅបានយ៉ាងមានតំលៃ។ វាក៏ស៊ីគ្នាយ៉ាងខ្លាំងទៅនិង "គោលការណ៍ នៃការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព" (Sustainable Livelihood Approach) ដែលរួមបញ្ចូលសមាសភាពមនុស្ស ហិរញ្ញវត្ថុ រូបវន្ត័ សង្គម និងធនធានធម្មជាតិទៅក្នុងការរៀបចំយ៉ាងជាក់លាក់មួយនៃគោលនយោបាយ ស្ថាបន័ និងដំណើរការអនុវត្តន៍ ដោយអាស្រ័យទៅលើបរិបទនៃនិរន្តរភាព ភាពងាយទទួលរងគ្រោះ និងភាពក្រីក្រ (សូមមើលនៅក្នុង www.livelihoods.org)។

គន្លឹះស្រាវជ្រាវ និង ការពិចារណាទៅលើគោលនយោបាយ ត្រូវបានផ្តល់អោយដើម្បីដោះស្រាយផលវិបាកនានានៅក្នុងទ្រង់ទ្រាយនៃអភិបាលកិច្ច សេដ្ឋកិច្ចសង្គម និងប្រពន្ធ័វារីអេកូឡូស៊ីរបស់បឹងទន្លេសាប។ ទាំងនេះ រួមបញ្ចូលទាំងការបង្កើននូវចំណេះដឹងអំពីប្រពន្ធ័អេកូឡូស៊ី និង ទំនាក់ទំនងរវាងសារៈសំខាន់នៃការប្រកបរបរ ចិញ្ចឹមជីវិតនិងអេកូឡូស៊ី និងការយល់ដឹងនូវការផ្លាស់ប្តូរជានិច្ចនៃសង្គម (social dynamics) រវាងអ្នកពាក់ពន្ធ័ទាំងឡាយ ដោយរួមបញ្ចូលអ្នកនេសាទតាមរដូវកាល និងមកពីកន្លែងផ្សេងៗ និង អ្នកនេសាទនៃក្រុមជនជាតិផ្សេងៗ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងទៅនិងជំលោះនៃសិទ្ធិ និង ការប្រើប្រាស់ធនធានធម្មជាតិ។ ការស្រាវជ្រាវស្តីអំពីការពង្រឹងការប៉ាន់ស្មានតំលៃរបស់ធនធានជលផល និង ប្រពន្ធ័វារីអេកូឡូស៊ីនៅក្នុងបឹងទន្លេសាបតាមរយៈការរួមបញ្ចូលតំលៃនៃការប្រើប្រាស់និងការមិនប្រើប្រាស់ផ្សេងៗទៀតត្រូវតែត្រូវការជាចាំបាច់។ ជាទីបញ្ចប់ ការពិចាណាទៅលើគោលនយោបាយ ចាំបាច់ត្រូវតែបញ្ជាក់អំពីភាពខុសគ្នានៃចំណូលរបស់គ្រួសារដែលពឹងផ្អែកទៅលើធនធានវារិជាត។

*តំរូវការនៃការស្រាវជ្រាវមួយចំនួន និង ការពិចារណាលើគោលនយោបាយផ្សេងៗត្រូវបានស្នើរឡើងដូចខាងក្រោម:*

- *បង្កើននូវចំណេះដឹងដឹងពីប្រពន្ធ័អេកូឡូស៊ី ឧទាហរណ៍ ទំនាក់ទំនងរវាងការបាត់បង់ជំរក និង ព្រៃ លិចទឹកហើយនិងផលប៉ះពាល់នៃឧបករណ៍នេសាទ និង សកម្មភាពដ៏ទៃទៀតទៅលើសុខភាពនិង ផលិតភាពរបស់បឹងទន្លេសាប។*
- *ការយល់ដឹងនូវការផ្លាស់ប្តូរជានិច្ចនៃសង្គម (social dynamics) រវាងអ្នកពាក់ពន្ធ័ រួមមានអ្នកមកពីកន្លែងផ្សេងៗ អ្នកនេសាទទៅតាមរដូវ និង អ្នកនេសាទដែលជាជនជាតិផ្សេងៗ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងការប្រើប្រាស់ឧបករណ៍នេសាទ បំផ្លិចបំផ្លាញនិងខុសច្បាប់ ទំនាស់ រវាងអ្នកពាក់ពន្ធ័ សិទ្ធិក្នុងការប្រើប្រាស់ធនធានទីផ្សារ និងប្រពន្ធ័ឥណទាន។*
- *បង្កើនការដឹងអំពីភាពខុសគ្នានៃប្រាក់ចំណូលដែលមានស្រាប់ ក្នុងចំណោមគ្រួសារទាំងនោះ ហើយនឹងធ្វើឱ្យប្រសើរឡើងលើការប៉ាន់ស្មាននៃតំលៃសេដ្ឋកិច្ចសរុបរបស់ធនធានជលផលនៃបឹងទន្លេសាប និង ប្រពន្ធ័វារីអេកូឡូស៊ីតាមរយៈការរួមបញ្ចូលនូវតំលៃទាំងអស់នៃតំលៃប្រើប្រាស់ និង តំលៃមិនប្រើប្រាស់។*

- *ពិនិត្យទៅលើជំរើសផ្សេងទៀត និង យុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិត ដើម្បីវាយតំលៃផលប៉ះពាល់នៃសកម្មភាពនានា និង ជំរើសផ្សេងៗនៃគោលនយោបាយ ដើម្បីធានានូវសុវត្ថិភាពស្បៀង អាហារ និង គុណភាពនៃជីវិតរស់នៅ ។*
- *ការយល់ដឹងអំពីតួនាទីនិងការចូលរួមរបស់ស្ត្រីទៅក្នុងការបង្កើតប្រាក់ចំណូល ដើម្បីទ្រទ្រង់ដល់ការចិញ្ចឹមជីវិត ក៏ដូចជាក្នុងការគ្រប់គ្រង និង ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត ។*
- *ពិនិត្យទៅលើប្រសិទ្ធភាពនៃកំណែទំរង់គោលនយោបាយដលផលទៅពេលថ្មីៗនេះ ជាពិសេសគឺ សំដៅទៅលើការបែងចែកផលប្រយោជន៍ និង បញ្ហាខាងក្នុង/ខាងក្រៅនៃអ្នកពាក់ព័ន្ធ ដើម្បីធ្វើការកែសំរួលឱ្យបានសមរម្យមួយនៅក្នុងការរៀបចំស្ថាប័ន និងរចនាសម្ព័ន្ធនៃការគ្រប់គ្រង ឬ អភិបាលកិច្ច ។*

# ឯកសារយោង


**ADB. 2005**. The Tonle Sap Basin Strategy. Asian Development Bank, Philippines. 44 p.

**Ahmed, M., Hap, N., Vuthy, L. and Tiongco, M. 1998**. Socio-economic assessment of freshwater capture fisheries of Cambodia: Report on a household survey. Mekong River Commission, Phnom Penh, Cambodia. 186 p.

**Baran, E. 2005**. Cambodian inland fisheries: facts, figures and context. WorldFish Centre, and Inland Fisheries Research and Development Institute, Phnom Penh, Cambodia. 49p.

**Baran, E., Jantunen, T. and Chong, C.K.** (in press). Values of inland fisheries in the Mekong River Basin. In: Neiland A.E. (ed.). River Fisheries Valuation: A Global Synthesis and Critical Review with Particular Reference to Developing Countries. Report for the Comprehensive Assessment of Water Management in Agriculture.

**Béné, C. 2003**. When fisheries rhyme with poverty: A first step beyond the old paradigm on poverty in small-scale fisheries. World Development 31(6): 949-975.

**Bonheur, N., Kosal, M., Kosal, M., Sour, K. and Song, S. L. 2005**. Towards a holistic approach to wetlands governance. The legal and institutional framework and economic valuation of wetland resources in Cambodia. p. 53-98. In: Oh et al. (eds.) Wetlands Governance in the Mekong Region: Country Reports on the Legal-Institutional Framework and Economic Valuation of Aquatic Resources. WorldFish Center, Penang, Malaysia.

**CFDO and DFID. 2004**. Policy Reform Impact Assessment, Cambodia: Impacts of the Fisheries Policy Reforms in Kampong Cham, Pursat and Takeo Provinces. 1° Round Assessment Report. Community Fisheries Development Office, Department of Fisheries with assistance from IMM Ltd., U.K., and Department of International Development. March 2004.

**DOF, 2004. Statistics of Fisheries Production 1980 to 2003**. Department of Fisheries, Ministry of Agriculture, Forestry and Fisheries. Cambodia.

**Israel, D.C., Ahmed, M., Hong, Y.B., and Chee, H.M. 2005**. Aquatic resources valuation and policies for poverty elimination in the Lower Mekong Basin. DFID and WorldFish Centre, Penang, Malaysia. 189 pp. + annexes.

**Keskinen, M. 2003**. The Great Diversity of Livelihoods? - Socio-economic survey of the Tonle Sap Lake. WUP-FIN Socio-Economic Studies on Tonle Sap 8, MRCS/WUP-FIN, Phnom Penh.

**Kooiman, J., Bavinck, M., Jentoft, S. and Pullin R. (eds.) 2005**. Fish for Life: Interactive Governance for Fisheries. Amsterdam University Press.

**MAFF-CNMC. 2003**. National Sector Review 2003: Fisheries Management. Ministry of Agriculture, Forestry and Fisheries (MAFF) in association with Cambodia National Mekong Committee (CNMC). 15 p.

**McKenney, B. and Tola, P. 2002**. Natural resources and rural livelihoods in Cambodia: a baseline assessment. Cambodian Development Resource Institute, Working Paper 23, 166 p.

**Rab, M.A., Hap, N., Ahmed, M., Keang, S.L., and Viner, K. 2005**. Socioeconomics and Values of Resources in Great Lake - Tonle Sap and Mekong - Bassac Area: Results from a Sample Survey in Kampong Chhnang, Siem Reap and Kandal Provinces. WorldFish Center, Penang, Malaysia. (Available at www.ifredi.org)

**Ratner, B.D., Ha, D.T., Kosal, M., Nissapa, A., and Chanphengxay, S. 2004**. Undervalued and Overlooked: Sustaining Rural Livelihoods through Better Governance of Wetlands. WorldFish Center Studies and Reviews 28. 24 p.

**UNDP. 2003**. Database of Commune Profile 2002. Ministry of Planning, Phnom Penh.

## វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប (IFReDI)

### ចក្ខុវិស័យ

ការអភិវឌ្ឍដោយចីរភាពនូវធនធានជលផលក្នុងដែននេសាទទឹកសាបនៃប្រទេសកម្ពុជា ដើម្បីបង្កើនសន្តិសុខស្បៀង និងវិបុលភាពសេដ្ឋកិច្ច ។

### បេសកកម្ម

ដើម្បីផ្តល់ព័ត៌មានវិទ្យាសាស្ត្រ និងការគាំទ្របច្ចេកទេស សំរាប់ការអភិវឌ្ឍ និងការគ្រប់គ្រងដោយនិរន្តរភាពនូវធនធានជលផល ក្នុងដែននេសាទទឹកសាបនៃប្រទេសកម្ពុជា ដោយផ្អែកលើការស្រាវជ្រាវ ជីវសាស្ត្រ និងសេដ្ឋកិច្ចសង្គម ។

### គោលដៅ

- ប្រមូល វិភាគ និងផ្សព្វផ្សាយតាមបែបវិទ្យាសាស្ត្រ នូវជីវសាស្ត្រ និងសេដ្ឋកិច្ចសង្គម ។
- អភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពជាតិសម្រាប់ការគ្រប់គ្រងនេសាទទឹកសាបដោយសមស្រប ។
- បង្កើនជាអតិបរមានូវប្រាក់ចំណូលរបស់អ្នកនេសាទ និងកសិករ ។
- ការប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព ។



អាគារលេខ ១៨៦, មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា,
ប្រអប់សំបុត្រលេខ ៥៨២, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២២០ ៨១៧
អ៊ីមែល: info@ifredi.org គេហទំព័រ: www.ifredi.org

## តំលៃសេដ្ឋកិច្ចសង្គម និង
## ការចិញ្ចឹមជីវិតនៃជលផលបឹងទន្លេសាប

ធនធានជលផលនៅក្នុងតំបន់បឹងទន្លេសាប គឺមានសារៈសំខាន់មិនអាចកាត់ថ្លៃបានទេ ហើយបានចូលរួមចំណែកយ៉ាងច្រើន (ប្រហែល៦០%) នៃផលិតផលនេសាទទឹកសាបសរុប។ អ្វីដែលមិនទាន់ត្រូវបានទទួលស្គាល់នោះគឺសារៈសំខាន់នៃ ប្រព័ន្ធអេកូឡូស៊ីធនធានវារិជាតរបស់បឹងទន្លេសាបចំពោះការចិញ្ចឹមជីវិតរបស់ប្រជាជនជាងមួយលាននាក់ដែលរស់នៅក្នុងនិងជុំវិញតំបន់នោះ ហើយព្រមទាំងពឹងផ្អែកយ៉ាងខ្លាំង (តែមិនទាំងស្រុងទេ)ទៅលើធនធានទាំងនោះ។ របាយការណ៍សង្ខេបនេះ គឺដកស្រង់ចេញពីការសិក្សាថ្មីៗមួយដែលផ្តល់នូវការប៉ាន់ស្មានតំលៃរបស់ធនធានជលផលនិងវារិជាត ចំពោះសហគមន៍ទាំងឡាយនៅក្នុងខេត្តទាំងប្រាំដែលមានព្រំប្រទល់ជាប់នឹងបឹង ទន្លេសាប ដូចជា ខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងកំពង់ធំ។ របាយការណ៍នេះបង្ហាញអោយឃើញថា គ្រួសារទាំងអស់នៅក្នុងតំបន់ទាំងនោះចូលរួមក្នុងសកម្មភាពប្រកបរបរ ចិញ្ចឹមជីវិត និង រកប្រាក់ចំណូលផ្សេងៗរួមមាន ការធ្វើនេសាទ ការកែច្នៃត្រី ការលក់ត្រី ការចិញ្ចឹមត្រី ការធ្វើស្រែ កម្មករ ប្រចាំថ្ងៃ និង ប្រមូលអុស ដោយឥតគិតអំពីមុខរបរចំបងរបស់ពួកគេឡើយ។ ចំណូលសរុបប្រចាំឆ្នាំនៃគ្រួសារដែលបានមកពីការប្រើប្រាស់ដោយផ្ទាល់ នៃភោគផលរបស់គ្រួសារដែលពឹងផ្អែកទៅលើធនធានជលផលនៅក្នុងខេត្តទាំងប្រាំត្រូវបានប៉ាន់ស្មានថាមានប្រហែលជា ២៣៣លានដុល្លារអាមេរិក។ មានតែមួយភាគបីនៃចំនួននោះតែប៉ុណ្ណោះដែលត្រូវទទួលបានដោយគ្រួសារ ដែលមានចំណូលតិចជាង ១.០០០ដុល្លារអាមេរិក ហើយដែលរួមមានប្រហែលជា ៧២% នៃចំនួនគ្រួសារសរុប។ ចំពោះគ្រួសារដែលមានចំណូលទាបទាំងនោះ គឺភាគច្រើនជាអ្នកនេសាទជាលក្ខណៈគ្រួសារ និងសំរាប់បរិភោគតែប៉ុណ្ណោះ និងកសិករដែលមានការចិញ្ចឹមជីវិតដោយពឹងផ្អែកយ៉ាងខ្លាំងទៅលើបឹងទន្លេសាប។ ជាការពិតណាស់ ទាក់ទងទៅនឹងរបរចិញ្ចឹមជីវិតរបស់ពួកគេ ដូចជាការធានានូវសិទ្ធិនៃការប្រើប្រាស់ធនធាននានានិងសិទ្ធិចាំបាច់ចំពោះសុវត្ថិភាពស្បៀង ការងារ ការអប់រំ និង ការរក្សាសុខភាពគួរតែត្រូវបានបញ្ជាក់អោយបានច្បាស់នៅក្នុងកិច្ចពិភាក្សាអំពីការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃធនធានជលផល និងប្រព័ន្ធវារីអេកូឡូស៊ីនៃ បឹងទន្លេសាប។

ISBN 999506502-9
9789995065027